

មហាអនុតំបន់មេគង្គៈ ការផ្តួចផ្តើមអភិរក្សតំបន់របៀងជីវចម្រុះ

# សារៈសំខាន់នៃ ការអភិរក្ស ព្រៃឈើ & សត្វព្រៃ នៅក្នុងខេត្តមណ្ឌលគិរី



២០០៨

ADB

**របាយការណ៍នេះរៀបរៀងដោយៈ**

**សួន ផល្លា, ហ៊ុយ គាឌុធ, ថម អ៊ីវ៉ាន** និង **អេដវ៉ត ផូឡា**

រចនាទំព័រដោយៈ Khmer Design Group

កែសម្រួលរចនាទំព័រដោយៈ កេក ណារ៉ាទេវី , អង្គការ WWF កម្ពុជា

សម្របសម្រួលការបោះពុម្ពផ្សាយដោយៈ កេក ណារ៉ាទេវី និងលោក លី សារ៉េត, អង្គការ WWF កម្ពុជា

នៅលើគ្របមុខ រូបភាពព្រៃឈើដោយលោក ថម អ៊ីវ៉ាន, អង្គការ WCS

រូបភាពសត្វជីវព្រៃដោយអង្គការ WWF

នៅលើគ្របក្រោយ រូបភាពដោយអង្គការ WWF

**អង្គការ WWF មហាតំបន់មេគង្គ - កម្មវិធីអភិរក្សនៅកម្ពុជា**

ផ្ទះលេខ៥៤ ផ្លូវលេខ៣៥២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទៈ (៨៥៥)២៣ ២១៨ ០៣៤ , ទូរសារៈ (៨៥៥)២៣ ២១១ ៩០៩

អ៊ីមែលៈ wwfcambodia@wwfgreatermekong.org

**អង្គការសមាគមអភិរក្សសត្វព្រៃ**

ផ្ទះលេខ២១ ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទៈ (៨៥៥)២៣ ២១៩ ៤៤៣ , ទូរសារៈ (៨៥៥) ២៣ ២១៧ ២០៥

អ៊ីមែលៈ cambodia@wcs.org

បោះពុម្ពផ្សាយឆ្នាំ ២០០៨

រក្សាសិទ្ធគ្រប់យ៉ាងដោយ WWF, WCS និង ADB

**កម្មវិធីនេះទទួលការឧបត្ថម្ភដោយធានាគារអភិវឌ្ឍន៍អាស៊ី**
**និងរដ្ឋាភិបាលនៃប្រទេសហ្វាំងឡង់ ហូឡង់ និងស៊ុយអែត ។**

# សេចក្តីថ្លែងអំណរគុណ


របាយការណ៍នេះមិនអាចបញ្ចប់បាន ប្រសិនបើគ្មានការផ្តល់មតិយោបល់ និងជួយកែសម្រួលខ្លឹមសារអត្ថបទពីសំណាក់ឯកឧត្តម អស់លោក លោកស្រី ជំនាញការបរទេស និងសហការីនៃអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) និងអង្គការមូលនិធិអភិរក្សធម្មជាតិ (WWF) ប្រចាំនៅកម្ពុជា។ សូមថ្លែងអំណរគុណជាពិសេសចំពោះ:

-ឯកឧត្តម **ទី សុគន្ធ** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងជាប្រធានរដ្ឋបាលព្រៃឈើដែលបានជួយគាំទ្រលើសំណើសុំបង្កើតតំបន់ព្រៃសម្រាប់ការពារ និងអភិរក្សធនធានជីវចម្រុះនៅក្នុងខេត្តមណ្ឌលគីរី។

-ឯកឧត្តម **ឡាយ សុខា** អភិបាលខេត្ត លោក **កែវ ហន** និងលោក **ចាន់ យឿន** អភិបាលរងខេត្តមណ្ឌលគីរី ដែលបានចូលរួមគាំទ្រដល់គម្រោងសកម្មភាពអភិរក្សព្រៃឈើ និងសត្វព្រៃ និងផ្តល់នូវអនុសាសន៍ល្អៗជាច្រើន។

សូមថ្លែងអំណរគុណផងដែរចំពោះលោក **ម៉ែន សុរិយន់** លោក **សេខ ឡៅក** លោក **មូល ផាត** លោក Bas Van Helvoort, Craig Bruce, និង Nick Cox ដែលបានចូលរួមផ្តល់មតិយោបល់លើរបាយការណ៍នេះ។ សូមអរគុណលោក **ព្រំ តុលា** ដែលបានជួយកែសម្រួលអត្ថបទ។

សារៈសំខាន់នៃ

ការអភិរក្ស

# ព្រៃឈើ
# &
# សត្វព្រៃ

នៅក្នុងខេត្តមណ្ឌលគិរី

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះមិនអាចបញ្ចប់បាន ប្រសិនបើគ្មានការផ្តល់មតិយោបល់ និងជួយកែសម្រួលខ្លឹមសារអត្ថបទពីសំណាក់ឯកឧត្តម អស់លោក លោកស្រី ជំនាញការបរទេស និងសហការីនៃអង្គការសមាគមអភិរក្សសត្វព្រៃ (WCS) និងអង្គការមូលនិធិអភិរក្សធម្មជាតិ (WWF) ប្រចាំនៅកម្ពុជា។ សូមថ្លែងអំណរគុណជាពិសេសចំពោះៈ

-ឯកឧត្តម **ឆឺ សុគន្ធ** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងជាប្រធានរដ្ឋបាលព្រៃឈើដែលបានជួយគាំទ្រលើសំណើសុំបង្កើតតំបន់ព្រៃសម្រាប់ការពារ និងអភិរក្សធនធានជីវចម្រុះនៅក្នុងខេត្តមណ្ឌលគិរី។

-ឯកឧត្តម **ឡាយ សុខា** អភិបាលខេត្ត លោក **កែវ ហាន** និងលោក **ចាន់ យឿន** អភិបាលរងខេត្តមណ្ឌលគិរី ដែលបានចូលរួមគាំទ្រដល់គម្រោងសកម្មភាពអភិរក្សព្រៃឈើ និងសត្វព្រៃ និងផ្តល់នូវអនុសាសន៍ល្អៗជាច្រើន។

សូមថ្លែងអំណរគុណផងដែរចំពោះលោក **ម៉ែន សុរិយន់** លោក **សេង ទៀក** លោក **មូល ផាត** លោក Bas Van Helvoort, Craig Bruce, និង Nick Cox ដែលបានចូលរួមផ្តល់មតិយោបល់លើរបាយការណ៍នេះ។ សូមអរគុណលោក **ព្រំ តុលា** ដែលបានជួយកែសម្រួលអត្ថបទ។

# មាតិកា


សេចក្តីផ្តើម .................................................. ២

ទម្រង់អត្ថបទ .................................................. ៤

១. លក្ខណៈនិងតំបន់សំខាន់ក្នុងការអភិរក្សជីវៈចំរុះលើសកលលោក ដែលទាក់ទងទៅនឹងខេត្តមណ្ឌលគិរី ..........៤

១.១ តំបន់ព្រៃធម្មជាតិចុងក្រោយ .................................................. ៤

១.២ តំបន់មានសក្តានុពលខ្ពស់សម្រាប់ជីវចម្រុះ ប្រភេទរុក្ខជាតិ និងសត្វសំខាន់ៗ ........................ ៧

១.៣ តំបន់សម្រាប់ប្រភេទសត្វស្លាបស្ពានិក .................................................. ៩

១.៤ តំបន់សត្វស្លាបសំខាន់ៗសម្រាប់អភិរក្ស .................................................. ១១

១.៥ មហាតំបន់អេកូឡូស៊ីជីវចម្រុះជួរភ្នំអាណាម៉ៃ .................................................. ១២

១.៦ តំបន់មានសក្តានុពលអភិរក្សសត្វខ្លាធំ .................................................. ១៧

២. ខេត្តមណ្ឌលគិរីៈតំបន់ដែលមានសារសំខាន់សម្រាប់ ជីវសាស្ត្រ និងតំបន់អភិរក្សសំខាន់ៗ ................ ២២

២.១ តំបន់អទិភាពអេកូឡូស៊ីនៃព្រៃល្បោះទន្លេមេគង្គក្រោម .................................................. ២២

២.២ តំបន់ជំរាលភាគខាងលិចនៃជួរភ្នំអាណាម៉ៃភាគខាងត្បូង .................................................. ២៤

២.៣ តំបន់សត្វស្លាបទឹកសំខាន់ៗ .................................................. ២៦

២.៤ តំបន់សម្រាប់ការអភិរក្សសត្វដំរី .................................................. ២៦

២.៥ ការកំនត់តំបន់សំខាន់ៗនៃជីវចម្រុះនៅក្នុងខេត្តមណ្ឌលគិរីផ្អែកលើទិន្នន័យនៃការសិក្សា ............. ២៦

២.៦ ស្ថានភាពតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃ .................................................. ២៨

# សេចក្តីផ្តើម

ខេត្តមណ្ឌលគីរីមានព្រំប្រទល់ខាងជើងទល់នឹងខេត្តរតនៈគីរី និងខេត្តស្ទឹងត្រែង ខាងលិចទល់នឹងខេត្តក្រចេះ ខាងត្បូងទល់នឹងខេត្តក្រចេះ និងប្រទេសវៀតណាម និងខាងកើតទល់នឹងប្រទេសវៀតណាម។ ខេត្តនេះមានស្រុកចំនួន៥ ឃុំចំនួន២១ និងភូមិចំនួន ៩១ ដែលមានចំនួនប្រជាជនសរុបប្រមាណ៤៧.៣៩១ នាក់ (ស្ថិតិក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០០៤)។ ខេត្តមណ្ឌលគីរីមានផ្ទៃដីសរុប១៤.២៨៨គម$^{២}$(NIS2005,DoG2005) ដែលក្នុងនោះផ្ទៃដីព្រៃឈើសរុបមានចំនួន១.២៤៩.៦៧២ហ.ត (ស្ថិតិព្រៃឈើ២០០៦)។ ខេត្តមណ្ឌលគីរីមានធនធានជីវៈចម្រុះសំបូរបែបជាពិសេសព្រៃឈើ និងសត្វព្រៃស្ទើរគ្រប់ប្រភេទ ដូចជា ដំរី ខ្លា ទន្សោង ខ្ទីង ទោច ក្ងោក ត្រគួត រញ្ជី ក្រពើ អណ្តើក....ជាដើម ដែលកំពុងរស់នៅក្នុងខេត្តនេះ។ តាមការប៉ាន់ស្មានជាទូទៅខេត្តនេះមានពពួកថនិកសត្វជិត ១០០ប្រភេទ សត្វស្លាបជិត៤០០ប្រភេទ និងឧរង្គសត្វជាង៥០ប្រភេទ។ ប្រភេទខ្លះមានសារៈសំខាន់ចំពោះការអភិរក្សជាលក្ខណៈសាកល និងប្រភេទខ្លះទៀតក៏មានសារៈសំខាន់ចំពោះការប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនធ្វើជាអាហារសម្រាប់ផលិតឱសថបុរាណរបស់សហគមន៍មូលដ្ឋាន និងការអភិរក្សនៅក្នុងតំបន់ផងដែរ។ ព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ព្រៃគម្ពោត ឬស្សី និងធម្មជាតិនៃជួរភ្នំ មិនគ្រាន់តែជាទី ជម្រកដ៏ល្អបំផុតសម្រាប់ពពួកសត្វព្រៃរស់នៅបន្តពូជ និងស្វែងរកចំណីប៉ុណ្ណោះទេ គឺថែមទាំងបានបង្ហាញនូវទេសភាពធម្មជាតិដ៏ល្អត្រកាលសម្រាប់ការអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិផងដែរ ។ ប្រៀបធៀបទៅនឹងតំបន់អភិរក្សជីវចម្រុះនានាដែលត្រូវបានបំផ្លាញទាំងស្រុងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ខេត្តមណ្ឌលគីរីមានលក្ខណៈពិសេសមួយទៀត គឺជាតំបន់ព្រៃធម្មជាតិចុងក្រោយសម្រាប់ជីវចម្រុះគ្រប់ប្រភេទប្រមូលផ្តុំគ្នារស់នៅបន្តពូជ និងរកចំណីតាមបែបធម្មជាតិ។ របាយការណ៍នេះនឹងអធិប្បាយសង្ខេបអំពីធនធានជីវចម្រុះសំខាន់ៗនៅក្នុងទឹកដីខេត្តមណ្ឌលគីរី ជាមួយសារៈសំខាន់របស់វាចំពោះការអភិរក្ស និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ជាពិសេសគឺការផ្តល់អនុសាសន៍ក្នុងការអភិរក្ស និងការអនុវត្តគម្រោងអភិរក្សសំខាន់ៗមួយចំនួនសម្រាប់ការការពារការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ផលអនុផលព្រៃឈើក្នុងខេត្តមណ្ឌគីរីនេះប្រកបដោយនិរន្តរភាព។

**តារាងទី១:** ប្រភេទព្រៃ និងគំរបព្រៃក្នុងខេត្តមណ្ឌលគីរី

| ល.រ | ប្រភេទព្រៃឈើ | ផ្ទៃដី (ហ.ត) |
|---|---|---|
| ១ | ព្រៃស្រោង | ១៦៣.៥៤៧ |
| ២ | ព្រៃពាក់កណ្តាលស្រោង | ១៧៨.១៩៩ |
| ៣ | ព្រៃល្បោះ | ៨៨១.៩៣៧ |
| ៤ | ព្រៃគម្ពោតស្ងួត | ៦.៣១២ |
| ៥ | ព្រៃគម្ពោតបែតងជានិច្ច | ២.៤២៣ |
| ៦ | ឫស្សី | ៤.៤៥៥ |
| ៧ | ព្រៃផ្សេងទៀត | ១២.៧៥០ |
| សរុប | ព្រៃឈើសរុប | ១.២៤៩.៦៧២ |

(ប្រភព: ស្ថិតិវិស័យព្រៃឈើត្រឹមឆ្នាំ ២០០៦ រដ្ឋបាលព្រៃឈើ


ទីតាំងគំរបព្រៃឈើឆ្នាំ ២០០៦
នៅខេត្តមណ្ឌលគិរី
0 25 50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA\MaFF, DoG\MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16º N)
Unit: Meter
សញ្ញាសំគាល់
សាលាស្រុក
ផ្លូវមេ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ផ្លូវទឹក
ព្រៃស្រោង Evergreen forest
ព្រៃពាក់កណ្តាលស្រោង Semi-evergreen forest
ដីព្រៃតាមដងអូរ Riparian forest
ព្រៃល្បោះ Deciduous forest
ព្រៃគម្ពោធ Woodland-shrub
ព្រៃដុះឡើងវិញ Secondary forest
ដំណាំឧស្សាហកម្ម Forest plantation
ដីមិនមានគំរបព្រៃ Non-forest
Sesan river
Srepok river
Mekong river
O Krieng
O Te
O Chhlong
Lao PDR
Thailand
Cambodia
Vietnam
600000 620000 640000 660000 680000 700000 720000 740000 760000 780000
1500000 1480000 1460000 1440000 1420000 1400000 1380000 1360000 1340000

# ទម្រង់អត្ថបទ

ទម្រង់អត្ថបទនេះអធិប្បាយអំពីសារៈសំខាន់ក្នុងការអភិរក្សព្រៃឈើ និងសត្វព្រៃក្នុងខេត្តមណ្ឌលគីរីដែលចែកចេញជាពីរផ្នែកសំខាន់ៗគឺៈ

- ផ្នែកទីមួយអធិប្បាយអំពីតំបន់អភិរក្សសំខាន់ៗនៅលើពិភពលោក និងលក្ខណៈពិសេសនានារបស់វាដែលក្នុងនោះខេត្តមណ្ឌលគីរីជាផ្នែកមួយរឺជាសក្តានុពលភាពមួយនៃតំបន់អភិរក្សសំខាន់ៗទាំងនេះ ។
- ផ្នែកទី២នៃអត្ថបទបទនេះបង្ហាញ និងគូសបញ្ជាក់អំពីខេត្តមណ្ឌលគីរីដែលមានសារៈសំខាន់ និងសក្តានុ-ពលភាពសំរាប់ការអភិរក្សជីវៈចម្រុះ និងអធិប្បាយអំពីតំបន់ការពារសំខាន់ៗដែលបង្កើតឡើងដោយព្រះរាជក្រិត្យ អនុក្រិត្យ និងប្រកាស ដែលនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ព្រមទាំងការកាត់តំបន់កាពារមួយចំនួនសំរាប់ធ្វើការអភិវឌ្ឍសេដ្ឋកិច្ច។



© WCS/E Pollard

ព្រៃស្រោង



© WCS/E Pollard

ព្រៃពាក់កណ្តាលស្រោង

## ១. លក្ខណៈនៃតំបន់សំខាន់ក្នុងការអភិរក្សជីវចម្រុះលើសាកលលោកដែលទាក់ទងទៅនឹងខេត្តមណ្ឌលគីរី

### ១.១ តំបន់ព្រៃធម្មជាតិចុងក្រោយ

ខេត្តមណ្ឌលគីរីត្រូវបានរាប់បញ្ចូលទៅក្នុងតំបន់ព្រៃធម្មជាតិចុងក្រោយក្នុងបណ្តាព្រៃចុងក្រោយរបស់ពិភពលោកដែលទទួលរងការបំផ្លាញតិចតួចបំផុត។

អង្គការ និងអ្នកវិទ្យាសាស្រ្តផ្នែកអភិរក្សជាច្រើនបានសិក្សាវិភាគអំពីឥទ្ធិពលរបស់មនុស្ស ការប្រើប្រាស់ធនធានធម្មជាតិនៅលើផែនដី និងស្ថានភាពនៃតំបន់ធម្មជាតិចុងក្រោយសម្រាប់សមាសភាពជីវចំរុះ។ លក្ខណៈវិនិច្ឆ័យមួយចំនួនដូចជាដង់ស៊ីតេប្រជាជនដែលរស់នៅក្នុងតំបន់ ការទន្ទ្រានដី ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ និងសំណង់វារីអគ្គីសនីនៅក្នុងតំបន់ ត្រូវបានក្រុមអ្នកវិទ្យាសាស្រ្តទាំងនោះលើកយកមកសិក្សាវិភាគ។ លទ្ធផលនៃការវិភាគបានបង្ហាញថាតំបន់ព្រៃខេត្តមណ្ឌលគីរីត្រូវបានរាប់បញ្ចូលទៅក្នុងចំណាត់ថ្នាក់នៃតំបន់ព្រៃធម្មជាតិចុងក្រោយដែលល្អជាងគេក្នុងចំណោមព្រៃធម្មជាតិចុងក្រោយ១០ភាគរយនៅលើពិភពលោក។

ឧទាហរណ៏ៈ ការសិក្សាវិភាគអំពីសកម្មភាព ឬឥទ្ធិពលមនុស្សទៅលើធនធានជីវចម្រុះនៅក្នុងតំបន់តែមួយ



© WCS/E Pollard

ព្រៃ និងចំការ



© WCS/E Pollard

ព្រៃល្បោះជ្រុះស្លឹក



© WCS/E Pollard

ព្រៃគុម្ពោតតាមដងទន្លេ

ដោយប្រើវិធីសាស្ត្រដាក់ពិន្ទុ ពី០ដល់១០។ ពិន្ទុ ០ (សូន្យ) មានន័យថាតំបន់ដែលទទួលឥទ្ធិពលពីមនុស្សតិចតួច និង១០ មានន័យថាតំបន់ដែលទទួលរងឥទ្ធិពលមនុស្សច្រើន ។ ករណីនេះក្រុមអ្នកវិទ្យាសាស្ត្រពិនិត្យមើលទៅលើដង់ស៊ីតេប្រជាជនរស់នៅលើផ្ទៃដីនៃតំបន់ព្រៃធម្មជាតិនោះផងដែរ។ ប្រសិនបើដង់ស៊ីតេមានត្រឹមតែ១០នាក់/គម² នោះ គេចាត់ទុកថាជាតំបន់ល្អប្រសើរសម្រាប់ជីវចម្រុះ និងដាក់ពិន្ទុ០។ រីឯដង់ស៊ីតេប្រជាជនក្នុងខេត្តមណ្ឌលគីរីគឺមានតែ២នាក់/គម² ។ ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានសិក្សាកន្លងមកអង្គការអភិរក្សនានាបានវាយតម្លៃថាតំបន់ព្រៃខេត្តមណ្ឌលគីរីទទួលរងការបំផ្លិចបំផ្លាញ និងទទួលសម្ពាធនៃការបរបាញ់តិចតួចនៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដូច្នេះព្រៃឈើក្នុងខេត្តមណ្ឌលគីរីគឺជាតំបន់ព្រៃធម្មជាតិចុងក្រោយដ៏ល្អប្រសើរបំផុតសម្រាប់ការអភិរក្សសត្វព្រៃ និងជីវៈចម្រុះដទៃទៀត[១]។

[១] (សូមអានអត្ថបទលំអិតរបស់ក្រុមលោក Eric W. Sanderson ស្តីពី The Human Footprint and the Last of the Wild, WCS ឆ្នាំ ២០០២)។

## តំបន់ព្រៃឈើចុងក្រោយ

### តំបន់ដែលមានសកម្មភាពមនុស្សតិចតួច និងមានសក្តានុពលខ្ពស់ជាសាកល សម្រាប់ការអភិរក្សទីជម្រកសត្វព្រៃ



## ១.២ តំបន់មានសក្តានុពលខ្ពស់សម្រាប់ជីវចម្រុះ ប្រភេទរុក្ខជាតិ និងសត្វសំខាន់ៗ

ខេត្តមណ្ឌលគិរីស្ថិតក្នុងឥណ្ឌូភូមាដែលមានរុក្ខជាតិកម្រ ប្រភេទថនិកសត្វព្រៃ និងមានសក្តានុពលភាពខ្ពស់សំរាប់អភិរក្សជីវៈចំរុះនៅលើផែនដី។

អ្នកវិទ្យាសាស្ត្រខាងវិស័យអភិរក្សបានធ្វើការសិក្សាវិភាគអំពីទីជម្រកធម្មជាតិដែលទទួលរងនូវការបំផ្លាញជាមួយនឹងប្រភេទរុក្ខជាតិស្លានិកដែលមាននៅក្នុងតំបន់នោះ ព្រមទាំងសិក្សាអំពីទំហំព្រៃ ឬទីជម្រកធម្មជាតិទាំងអស់ដែលមានវត្តមាននៅលើផែនដី ។ ទីជម្រកធម្មជាតិដែលមានសក្តានុពលសម្រាប់ជីវចម្រុះទាំងអស់មានចំនួន២៥កន្លែងនៅលើផែនដី ដែលមានទំហំប្រហែល ១.៤ ភាគរយ នៃផែនដីសរុប។ក្នុងចំណោម ២៥កន្លែងនេះ មានតំបន់ជីវចម្រុះ១២កន្លែងដែលមានព្រំប្រទល់ឆ្លងកាត់ប្រទេស២ ឬច្រើនដូចជាតំបន់ជីវចម្រុះឥណ្ឌូភូមា (Indo-Burma ) ដែលគ្របដណ្តប់លើប្រទេសទាំងអស់ក្នុងអនុតំបន់ទន្លេមេគង្គ ។ ពពួករុក្ខជាតិ និងសត្វព្រៃនៃតំបន់ឥណ្ឌូភូមានេះមានទំហំសរុប ២.០៦០.០០០គម$^{២}$ដែលមានរុក្ខជាតិ ១៣.៥០០ប្រភេទ និងសត្វព្រៃចម្រុះ២.១៨៥ប្រភេទ។រុក្ខជាតិស្លានិកក្នុងតំបន់នេះមាន ៧០០០ប្រភេទស្មើនឹង ២.៣ភាគរយធៀបនឹងប្រភេទស្លានិកទាំងអស់នៅលើផែនដីចំនួន ៣០០.០០០ប្រភេទ និងស្លានិកប្រភេទសត្វមាន ៥២៨ ប្រភេទ ស្មើនឹង ១.៩ ភាគរយធៀបនឹងប្រភេទស្លានិកទាំងអស់លើផែនដីចំនួន ២៧.២៩៨ប្រភេទ។លទ្ធផលនៃការវិភាគនេះបានបង្ហាញថា តំបន់សក្តានុពលជីវចម្រុះ ១១កន្លែង បានបាត់បង់ប្រភេទស្លានិកសំខាន់ៗចំនួន៩០ភាគរយ និងចំនួន៣កន្លែងទៀតបានបាត់បង់ ៩៥ភាគរយ។

ខេត្តមណ្ឌលគិរីស្ថិតនៅក្នុងតំបន់ឥណ្ឌូភូមា ដែលមានប្រភេទរុក្ខជាតិកម្រ និងប្រភេទស្លានិកសត្វព្រៃជាច្រើនកំពុងដុះលូតលាស់ និងរស់នៅលើផ្ទៃដីតំបន់ទេសភាពដ៏ធំមហិមា និងជាទីជម្រកធម្មជាតិដ៏ល្អប្រសើរបំផុតសម្រាប់ការអភិរក្សប្រភេទស្លានិករុក្ខជាតិ និងសត្វព្រៃ ព្រោះព្រៃឈើ និងសត្វព្រៃក្នុងខេត្តមណ្ឌលគិរីមិនទទួលរងការបាត់បង់ ឬបំផ្លាញដូចតំបន់ទាំង ១៤ កន្លែងខាងលើឡើយ[២]។


© WCS/E Pollard

ទេសភាពពីលើនៃតំបន់អេកូឡូស៊ីអាណាម៉ៃ

[២] (សូមអានអត្ថបទលំអិតរបស់ក្រុមលោក Norman Myers ស្តីពី Biodiversity hotspots for conservation priorities, CI ឆ្នាំ ២០០០)។

## តំបន់ជីវចម្រុះ
## តំបន់ដែលមានសក្ដានុពលខ្ពស់ជាសាកលសម្រាប់ការអភិរក្សជីវចម្រុះដែលកំពុងរងគ្រោះថ្នាក់





© Ron Hoff

មាន់ទោពណ៌ប្រាក់ប្រផេះបៃតង ដែលមានរាយប៉ាយ
រស់នៅតែក្នុងតំបន់ភាគខាងត្បូងនៃតំបន់អេកូឡូស៊ីអាណាម៉ៃ

## ១.៣ តំបន់សម្រាប់ប្រភេទសត្វស្លាបស្ថានិក

ខេត្តមណ្ឌលគិរីជាតំបន់ជំរករបស់សត្វស្លាប ថនិកសត្វជិតផុតពូជកំពុងរងគ្រោះថ្នាក់ និងងាយរងគ្រោះជាសកលនៅលើផែនដី ។

អង្គការជីវិតបក្សីអន្តរជាតិ (Birdlife International) និងអ្នកវិទ្យាសាស្ត្រអភិរក្សអន្តរជាតិបានសិក្សាវាយតម្លៃតំបន់ពិសេសដែលមានវត្តមានប្រភេទស្ថានិកសត្វស្លាបរស់នៅលើពិភពលោកសម្រាប់កំណត់ជាអទិភាពក្នុងការអនុវត្តគម្រោងអភិរក្ស។ ការសិក្សានេះផ្អែកលើប្រភេទសត្វស្លាបណាដែលមានវត្តមានរស់នៅក្នុងតំបន់តែមួយមានប្រវត្តិរស់នៅយូរឆ្នាំ និងមានទំហំផ្ទៃដីតាមកំហិតជាក់លាក់មួយ ឧទាហរណ៍ ក្នុងរង្វង់ដែន ៥០.០០០គម$^{២}$ ឬ ១០០.០០០គម$^{២}$។ លទ្ធផលនៃការសិក្សារបស់អង្គការនេះក្នុងទសវត្សនៃឆ្នាំ ១៩៩០ បានបង្ហាញថាប្រភេទសត្វស្លាបស្ថានិកទាំងអស់មាន២.៦២៣ប្រភេទ ស្មើនឹង២៧ភាគរយនៃប្រភេទបក្សីទាំងអស់រស់នៅលើផែនដី និងនៅក្នុងនោះមាន៦២ប្រភេទបានវិនាសផុតពូជហើយ។

ក្រុមអ្នកវិទ្យាសាស្ត្របានរកឃើញប្រភេទស្ថានិក៣ប្រភេទដែលមានវត្តមានរស់នៅក្នុងតំបន់ដីសណ្តភាគខាងត្បូងប្រទេសវៀតណាមដែលតំបន់នោះមានផ្ទៃដី៣០.០០០គម២ និងមានព្រំប្រទល់ជាប់នឹងស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី។ ប្រភេទទាំងបីនេះ រួមមាន មាន់ទោប្រាក់ពណ៌ប្រផេះបៃតង (*Poleplectron germaini*) ទទាទ្រូងលឿង (*Arborophila divadi*) និងចាបដូនតាថ្ពាល់ប្រផេះ (*Macronous kelleyi*)។ ទទាទ្រូងលឿង ត្រូវបានអង្គការសហភាពអភិរក្សពិភពលោកចុះក្នុងបញ្ជីសៀវភៅក្រហមថាជាប្រភេទជិតផុតពូជបំផុត(Critical Endangered) និងប្រភេទមាន់ទោប្រាក់ពណ៌ប្រផេះបៃតងបានចុះក្នុងបញ្ជីសៀវភៅក្រហមថា ជាប្រភេទងាយរងគ្រោះថ្នាក់ជាសាកល (Vunerable) និងចាបដូនតាថ្ពាល់ប្រផេះបានចុះបញ្ជីនៃសៀវភៅក្រហមថាជាកំពុងរងគ្រោះថ្នាក់ (Globally Threatened)។ ថ្វីត្បិតតែនៅក្នុងទសវត្សនៃឆ្នាំ១៩៩០ នោះ អ្នកវិទ្យាសាស្ត្រមិនបានចុះស្រាវជ្រាវនៅខេត្តមណ្ឌលគិរី ប៉ុន្តែនៅពេលថ្មីៗនេះអង្គការអភិរក្ស និង-អ្នកវិទ្យាសាស្ត្រអន្តរជាតិបានរកឃើញ និងបញ្ជាក់អះអាងថាប្រភេទទាំងនេះក៏មានវត្តមានរស់នៅក្នុងខេត្តមណ្ឌលគិរីដែរ ជាពិសេសប្រភេទទាំងបីខាងលើនេះកំពុងមានវត្តមានរស់នៅក្នុងស្រុកកែវសីម៉ា ។ ប្រភេទសត្វស្លាបស្ថានិកពីរទៀតត្រូវបានរក ឃើញមានវត្តមាននៅតំបន់ភ្នំក្រវាញភាគខាងលិចនៃ ប្រទេសកម្ពុជា គឺត្រួចសំពៅ(*Arborophila cambodiana*) និងចក៌វិកកម្ពុជា (Cambodian Laughingthrush *Garrulax ferrarius*)។ ដូច្នេះព្រះរាជាណាចក្រកម្ពុជាមានតំបន់ព្រៃស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី ជាតំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ធ្វើការអភិរក្សប្រភេទសត្វស្លាប ស្ថានិក និងធនធានជីវចម្រុះដទៃទៀត[៣]។

[៣] (សូមអានសៀវភៅរបស់ក្រុមលោក Alison J. Stattersfield ស្តីពី Endemic Bird Areas of the World, ***Priorities for Biodiversity Conservation***, Birdlife International, page 450-453 ឆ្នាំ ១៩៩៨)។

## តំបន់សំខាន់សម្រាប់ប្រភេទឧស្ថានិករស់នៅ

## តំបន់ដែលមានសក្តានុពលខ្ពស់ជាសាកល សម្រាប់ការ អភិរក្សពពួកបក្សីដែលរស់នៅតែក្នុងតំបន់តូចមួយជាក់លាក់ប៉ុណ្ណោះ





សត្វខ្ទប់ដីមេគង្គលើ ដែលមាននៅតែតាមដងទន្លេមេគង្គក្រោមតែប៉ុណ្ណោះ

## ១.៤ តំបន់សត្វស្លាបសំខាន់ៗសម្រាប់អភិរក្ស

ខេត្តមណ្ឌលគិរីត្រូវបានចាត់ទុកជាជំរករបស់សត្វស្លាបសំខាន់ៗសំរាប់ធ្វើការអភិរក្សរួមមានប្រភេទកំរជិតផុតពូជប្រភេទរងគ្រោះថ្នាក់ជាសកល និងប្រភេទកំពុងរងគ្រោះថ្នាក់។

អង្គការជីវិតសត្វស្លាបអន្តរជាតិបានសិក្សា និងចាត់ថ្នាក់តំបន់សត្វស្លាបសំខាន់ៗសម្រាប់កំណត់អទិភាពអនុវត្តគម្រោងអភិរក្សនៅកម្ពុជា។ ការចាត់ថ្នាក់នេះផ្អែកលើលក្ខណៈវិនិច្ឆ័យតាមស្តង់ដាសាកលរបស់អង្គការ ដោយកំណត់យកសត្វស្លាបសំខាន់ៗធ្វើជាសន្ទស្សន៍ដើម្បីកំណត់តំបន់ ឬទីជម្រកសំខាន់ៗរបស់សត្វស្លាប ជាពិសេសគឺការបែងចែកទៅតាមក្រុមប្រភេទផ្សេងៗរបស់សត្វស្លាបដែលមានវត្តមានរស់នៅ។ លទ្ធផលនៃការសិក្សានោះបានបង្ហាញថា ប្រទេសកម្ពុជាមានផ្ទៃដី ប្រហែល ៤.៤០០.០០០ហិកតា ស្មើនឹង២៤ភាគរយនៃផ្ទៃដីសរុប ជាតំបន់សម្រាប់សត្វស្លាបសំខាន់ៗ(IBA)រស់នៅ និងរកចំណី។ ក្នុងនោះផ្ទៃដីទំហំធំជាង២០០.០០០ហិកតា មាន ៩កន្លែង និងផ្ទៃដីដែលមានទំហំធំជាង ៥០០.០០០ ហិកតា មាន២កន្លែង។ ខេត្តមណ្ឌលគីរីមានតំបន់សត្វស្លាបសំខាន់ៗចំនួនពីរកន្លែង គឺតំបន់ព្រៃរងទឹកភ្លៀងទន្លេស្រែពកភាគខាងជើង និងតំបន់ទំនាបភាគខាងត្បូង។

តំបន់ព្រៃរងទឹកភ្លៀងទន្លេស្រែពកខាងលើមានទំហំ ៥០៧.៧១១ហិកតា មានទីជម្រកស្ថិតនៅក្នុងស្រុកកោះញែក និងស្រុកពេជ្រដា និងទីជម្រកខ្លះស្ថិតនៅជាប់ជាមួយស្រុកលំផាត់ និងស្រុកអូរយ៉ាដាវនៃខេត្តរនៈគីរី។ តំបន់នេះមានប្រភេទសត្វទទួលរងគ្រោះថ្នាក់ជាសាកលច្រើនដែលជាប់ក្នុងចំណាត់ថ្នាក់ A1 (Globally threatened species) ប្រភេទប្រមូលផ្តុំគ្នានៅក្នុងតំបន់តែមួយA3 (Biome-restricted assemblages) និងមានប្រភេទប្រមូលផ្តុំជាហ្វូងធំៗ A4i (Congragations) (មើលតារាងទី២)។

**តារាងទី២:** ប្រភេទសត្វកំពុងរងគ្រោះថ្នាក់ជាសាកលដែលមានវត្តមានក្នុងខេត្តមណ្ឌលគីរី

| ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | លក្ខណៈវិនិច្ឆ័យ IBA |
|---|---|---|---|
| ក្ងោក | *Pavo muticus* | Green Peafowl | A1 |
| កេងកងធំ | *Buceros bicornis* | Great Hornbill | A1 |
| ក្រៀល | *Grus antigone* | Sarus Crane | A1 |
| ត្មាតខ្នោត | *Gyps tenuirostris* | Slender-billed Vulture | A1 |
| ត្មាតផេះ | *Gyps bengalensis* | White-rumped Vulture | A1 |
| ត្មាតភ្លើង | *Sarcogyps calvus* | Red-headed Vulture | A1 |
| ត្រដក់តូច | *Leptoptilos javanicus* | Lesser Adjutant | A1 |
| ត្រយ៉ងចំកឹកស | *Pseudibis davisoni* | White-shouldered Ibis | A1 |
| ត្រយ៉ងយក្ស | *Pseudibis gigantea* | Giant Ibis | A1 A4i |

| | | | |
|---|---|---|---|
| ទាព្រៃស្លាបស | *Cairina scutulata* | White-winged Duck | A1 |
| ពពូលទឹក | *Heliopais personata* | Masked Finfoot | A1 |
| ស្មោញ | *Anhinga melanogaster* | Darter | A1 |
| អកត្រីក្បាលប្រផេះ | *Ichthyophaga ichthyaetus* | Grey-headed Fish Eagle | A1 |
| អកត្រីតូច | *Ichthyophaga humilis* | Lesser Fish Eagle | A1 |


© WCS/S Visal

ពពូលទឹក


© Allan Michaud

ត្រយងយក្ស នៅលើពិភពលោក មានរបាយរស់នៅតែក្នុងប្រទេស កម្ពុជាប៉ុណ្ណោះ រួមទាំងក្នុងខេត្តមណ្ឌលគីរីផងដែរ

តំបន់ព្រៃទំនាបមណ្ឌលគីរី និងក្រចេះមានទំហំ ៣៨៣.២៣៣ហិកតា មានទីជម្រកស្ថិតនៅក្នុងស្រុកកែវសីម៉ាពេជ្រដា និងស្រុកស្នួល។ ព្រៃពាក់កណ្តាលស្រោងព្រៃល្បោះទំនាបវាលស្មៅ ត្រពាំង និងអូរជាទីកន្លែងមានសក្តានុពល និងអំណោយផលល្អដល់ពពួកសត្វព្រៃ។

ដូច្នេះតំបន់ព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ ស្ទឹង ទន្លេ និងត្រពាំងនានានៅក្នុងខេត្តមណ្ឌលគីរី បង្កើតបានជាមជ្ឈដ្ឋានរស់នៅដ៏ល្អសម្រាប់ការរស់នៅ និងរកចំណីរបស់ពពួកសត្វស្លាបកម្រៗ និងប្រភេទដែលរងគ្រោះថ្នាក់ជាសាកលច្រើន។ ការអភិរក្សទីជម្រក និងពពួកសត្វទាំងនេះត្រូវតែចាត់ទុកជាអទិភាព និងអនុវត្តជាបន្ទាន់[៤]។

## ១.៥ មហាតំបន់អេកូឡូស៊ីជីវចម្រុះជួរភ្នំអាណាម៉ៃ

ប្រទេសកម្ពុជាជាពិសេសផ្នែកខ្លះនៃខេត្តមណ្ឌលគីរីត្រូវបានចាត់ចូលក្នុងតំបន់អេកូឡូស៊ីសាកលទាំង២០០។

អង្គការអភិរក្ស និងអ្នកវិទ្យាសាស្ត្រអន្តរជាតិបានសិក្សាវិភាគតំបន់អេកូឡូស៊ីនៅលើផែនដីដោយបានបែងចែកចេញជាតំបន់អេកូឡូស៊ីធំៗជាច្រើន ហើយផ្នែកសំខាន់ៗនៃតំបន់អេកូឡូស៊ីនីមួយៗត្រូវបានវាយតម្លៃនូវសក្តានុពលប្រព័ន្ធអេកូឡូស៊ីរបស់វា។ ប្រសិនបើការអភិរក្សទទួលបានជោគជ័យនៅតំបន់នីមួយៗ នោះផ្នែកធំមួយនៃធនធានអេកូឡូស៊ីនៅលើផែនដីនៃតំបន់នោះនឹងមានសុវត្ថិភាពផងដែរ។

ជំហានទីមួយ គឺការបកស្រាយអេកូឡូស៊ីលើផែនដីតាមគម្របព្រៃធម្មជាតិនៅលើផែនទី។ ការវិភាគនេះបានរកឃើញតំបន់អេកូឡូស៊ីចំនួន៨៦៧តំបន់ និងបានរៀបរាប់តាមជំពូកនានានៅក្នុងសៀវភៅស្តីពីតំបន់អេកូឡូស៊ីបោះពុម្ពដោយក្រុមរបស់លោក (Wikramanayak *et al.* ២០០២)។

ជំហានបន្ទាប់ គឺការវិនិច្ឆ័យរកតំបន់អេកូឡូស៊ីណាដែលមានសារៈសំខាន់ជាងគេ។ តំបន់ដែលមានសារៈ

[៤] (សូមអានអត្ថបទលំអិតរបស់ក្រុមលោកសេង គឹមហ៊ត់ Colin M. Poole ស្តីពីតំបន់សត្វស្លាបសំខាន់ៗសម្រាប់ការអភិរក្ស Directory of Important Bird Areas in Cambodia, Key sites for Conservation, WCS and Birdlife International, ឆ្នាំ ២០០៣)។



© WWF

ដំរី (អាស៊ី)

សំខាន់ជាងគេនោះ ផ្អែកលើមូលដ្ឋាននៃកត្តាជីវមួយចំនួន ដូចជាភាពសម្បូរបែបនៃប្រភេទស្ថានិក លក្ខណៈទោលរបស់ប្រភេទ(មានតែមួយ) ភាពមិនប្រក្រតីនៃជីវសាស្ត្ររបស់ប្រភេទនានា និងភាពកម្រកបាននៅក្នុងពិភពលោក។ តំបន់សំខាន់ទាំងអស់មាន ២៣៣តំបន់ត្រូវបានជ្រើសរើស និងចាត់ចូលទៅក្នុងបញ្ជីមួយហៅថា "តំបន់អេកូឡូស៊ីសាកលទាំង២០០"។ ប្រទេសកម្ពុជាមានផ្នែកសំខាន់ៗទាំងបីនេះដូចខាងក្រោម:

ក- តំបន់ឥណ្ឌូចិនភាគខាងកើតនៃព្រៃស្ងួត និងរងទឹកភ្លៀងរបបខ្យល់មូសុង

ខ- តំបន់ព្រៃសើមនៃជួរភ្នំអាណាម៉ៃ (ភាគខាងលើនៃប្រទេសឡាវ វៀតណាម និងកម្ពុជា)

គ- តំបន់ព្រៃសើម(ស្រោង) ជួរភ្នំក្រវាញ។
លក្ខណៈសំខាន់នៃតំបន់ទី(ក)និងទី(ខ)ខាងលើមានគ្របដណ្តប់លើដីខេត្តមណ្ឌលគិរី។

ព្រៃស្រោង និងព្រៃល្បោះដុះលូតលាស់ចូលគ្នាបង្កើតបានពណ៌ចម្រុះស្ថិតនៅតាមបណ្តោយព្រំប្រទល់រវាងតំបន់អេកូឡូស៊ីទាំងពីរប្រភេទខាងលើដែលជាហេតុធ្វើឱ្យគេពិបាកកំណត់ព្រំដែនពិតប្រាកដរវាងតំបន់ទាំងពីរ។

ក្រុមអ្នកវិទ្យាសាស្ត្រក៏បានសិក្សាវាយតម្លៃលំអិតនៅក្នុងតំបន់។ ការសិក្សានេះបានពិនិត្យមើលទូទាំងប្រទេសកម្ពុជារួមទាំងភាគខាងត្បូង និងភាគកណ្តាលនៃប្រទេសវៀតណាម និងប្រទេសកម្ពុជាដែលបានឱ្យឈ្មោះថាតំបន់ព្រៃមេគង្គក្រោម។ តំបន់នេះគ្របដណ្តប់លើតំបន់អេកូឡូស៊ីសំខាន់ទាំងបីខាងលើនៃតំបន់សាកលទាំង ២០០ ព្រមទាំងតំបន់ដទៃទៀតដែលស្ថិតនៅចន្លោះតំបន់ទាំងនោះ (Baltzer, Nguyen Thi Dao and Shore ២០០១) ការវាយតម្លៃតំបន់នេះ មានអ្នកវិទ្យាសាស្ត្រជាង៨០នាក់ដែលមកពីប្រទេសផ្សេងៗចូលរួមកែសម្រួលទិន្នន័យពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់តំបន់អេកូឡូស៊ី ព្រម-ទាំងវិនិច្ឆ័យកំណត់ទីតាំងជាក់លាក់នៅតំបន់អេកូឡូស៊ីនីមួយៗ ។ ការកំណត់នេះគឺជាប្រភពទិន្នន័យល្អបំផុតនៃការបែងចែកតំបន់ព្រៃសើមជួរភ្នំអាណាម៉ៃ ហើយក្រោយមកតំបន់នេះត្រូវបានដាក់ឈ្មោះថាមហាតំបន់អេកូឡូស៊ីជួរភ្នំអាណាម៉ៃ (The Greater Anamites Ecoregion)។

ដំណាក់កាលនៃការវិភាគមួយទៀតត្រូវបានបញ្ចប់នៅក្នុងតំបន់ឥណ្ឌូចិនភាគខាងកើតនៃព្រៃស្ងួត និងរងទឹកភ្លៀងរបបខ្យល់មូសុងដែលបច្ចុប្បន្នតំបន់នេះត្រូវ



© Nick Cox

តំបន់អេកូឡូស៊ីនៃព្រៃល្បោះជ្រុះស្លឹកនៃមេគង្គក្រោម

## តំបន់អេកូឡូស៊ីសាកលទាំង ២០០:
## តំបន់ដែលមានសក្តានុពលខ្ពស់ជាសាកលសម្រាប់ការអភិរក្សជីវចម្រុះដែល កំពុងរងគ្រោះថ្នាក់





© H Neilsen

ទាព្រៃស្លាបស

បានប្តូរឈ្មោះថា តំបន់ព្រៃស្ងួតផ្នែកខាងក្រោមទន្លេមេគង្គ (Lower Mekong Dry Forest Ecoregion)។ ទិន្នន័យបន្ថែម និងកែសម្រួលថ្មីសម្រាប់តំបន់អេកូឡូស៊ីក្នុងឆ្នាំ ២០០៣-២០០៥នោះ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនទីកំណត់តំបន់អាទិភាពរបស់អង្គការ WWF ក្នុងឆ្នាំ២០០៦កន្លងមក។

សេចក្តីសង្ខេបអំពីសារៈសំខាន់នៃតំបន់អេកូឡូស៊ីជួរភ្នំអាណាម៉ៃ (សូមអានអត្ថបទលោក Baltzer et al. ទំព័រ ១៣-១៦) មានដូចខាងក្រោមៈ

## លក្ខណៈភូមិសាស្ត្រ

ក- គ្របដណ្តប់ដោយតំបន់ព្រៃជួរភ្នំអាណាម៉ៃភាគច្រើនស្ថិតនៅរយៈកំពស់ ២០០-២០០០ ម៉ែត្រ។

ខ- ប្លុកភ្នំធំៗបី តំបន់ខ្ពង់រាប និងវាលទំនាបដែលស្ថិតនៅក្បែរ ។

គ- ភាគខាងត្បូង និងខាងកើត ដែលមានភ្លៀងច្រើន គឺជាតំបន់ដែលមានព្រៃស្រោងបៃតងជានិច្ច។

ឃ- ភាគខាងលិច និងខាងជើង ដែលរាំងស្ងួតមាន ខេត្តមណ្ឌលគិរីនៅក្នុងនោះ) គឺជាតំបន់មានព្រៃពាក់កណ្តាលស្រោងភាគច្រើន។

ង- ភាគផ្សេងៗគ្នានៃតំបន់អេកូឡូស៊ី ឧទាហរណ៍ ខាងជើង កណ្តាល និងខាងត្បូង) ក៏មានប្រភេទស្ថានិកផ្សេងៗគ្នាដែរ។

ច- ខេត្តមណ្ឌលគិរី ស្ថិតនៅក្នុងភាគខាងត្បូងនៃតំបន់អេកូឡូស៊ីដែលភាគខាងត្បូងនេះក៏មានបញ្ចូលតំបន់ខ្ពង់រាបដាឡាត់ (Dalat Plateau) ប្រទេសវៀតណាមដែរ។

ឆ- គេគិតថា ដោយសារតែតំបន់ភ្នំទាំងនេះទទួលទឹកភ្លៀងច្រើនដែលមានអំណោយផលល្អដល់ព្រៃស្រោងមានវត្តមានយូរឆ្នាំមកហើយសូម្បីតែអំឡុងពេលអាកាសធាតុក្នុងតំបន់អាស៊ីមានភាពរាំងស្ងួតកន្លងមករួចហើយក៏ដោយ។ វាបង្កើតបានជាទីជម្រកធម្មជាតិមួយដែលមានអំណោយផលល្អដល់ការរស់រាននៃប្រភេទសត្វព្រៃ និងការលូតលាស់នៃជីវិតធម្មជាតិទាំងឡាយ។

## ជីវសាស្ត្រ

ក- ក្នុងតំបន់អេកូឡូស៊ីទាំងមូលមានទីជម្រកផ្សេងៗគ្នារួមទាំងដីសើម និងព្រៃពាក់កណ្តាលស្រោង ប្រភេទព្រៃដែលមាននៅតែតំបន់ភ្នំ ប្រភេទព្រៃតាមជ្រលងភ្នំខ្ពស់ និងប្រភេទព្រៃស្រល់។

ខ- មានប្រភេទព្រៃបីក្នុងចំណោមប្រភេទខាងលើនេះកំពុងមានវត្តមាននៅខេត្តមណ្ឌលគិរី គឺព្រៃពាក់កណ្តាលស្រោង(ភាគច្រើននៅក្នុងតំបន់អភិរក្សជីវៈចម្រុះ "សីម៉ា" ស្រុកកែវសីម៉ា) ព្រៃវាលទំនាបតាមតំបន់ភ្នំភាគច្រើននៅតាម (ភ្នំណាមលៀ) និងវាលស្មៅតាមចន្លោះព្រៃទាំងឡាយភាគច្រើនមាននៅខាងក្រៅតំបន់ការពារ)។

គ- មានព្រៃឈ្មោះជ្រុះស្លឹកជាច្រើននៅភាគខាងត្បូងនៃមហាតំបន់អេកូឡូស៊ីអាណាម៉ៃ ជាពិសេសមាននៅក្នុងប្រទេសវៀតណាម។ ប៉ុន្តែតំបន់ព្រៃពាក់កណ្តាលស្រោងតាមតំបន់ទំនាបដែលនៅល្អ និងធំជាងគេនោះភាគច្រើនមាននៅក្នុងប្រទេសកម្ពុជា។

ឃ- មានវត្តមានប្រភេទកម្រ និងប្រភេទរងគ្រោះថ្នាក់ជាច្រើនដែលមានវត្តមានរស់នៅក្នុងតំបន់នេះ។ ឧទាហរណ៍ នៅក្នុងខេត្តមណ្ឌលគិរីមានប្រភេទ ខ្លា ខ្លាឃ្មុំ ខ្លារខិន ខ្ទីង ដំរី ក្ទោក និងទាព្រៃស្លាបសជាដើម។



© M Hunt

ទោចថ្ពាល់លឿង មានរបាយរស់នៅច្រើនជាងគេ នៅភាគខាងត្បូង នៃខេត្តមណ្ឌលគិរី

ង- ព្រមទាំងមានវត្តមានប្រភេទស្លានិកនៅក្នុងខេត្តមណ្ឌលគិរីនេះផងដែរដូចជា ស្វាក្រវ៉ាត់ ទោចថ្ពាល់លឿង ឈ្លូសយក្ស រញ្ជីប្រផេះ មាន់ទោប្រាក់ពណ៌ប្រផេះបៃតង ទទាទ្រូងលឿង និងចក់វែកកម្ពុជាដែលប្រភេទទាំងនេះកំពុងរងគ្រោះថ្នាក់។

ច- ការចុះអង្កេតស្រាវជ្រាវមិនទាន់គ្រប់គ្រាន់នៅឡើយទេប្រហែលជានៅមានប្រភេទច្រើនទៀតដែលអាចនឹងរកឃើញក្នុងពេលស្រាវជ្រាវលើកក្រោយ។ ក្រុមអ្នកវិទ្យាសាស្ត្រអភិរក្សបានធ្វើផែនទីមួយដែលគូសបញ្ជាក់អំពីអទិភាពនៃតំបន់ទេសភាព គឺផែនទីលេខ SA8 ដែលមានគម្របព្រៃប៉ែកខាងលិចនៃតំបន់អាណាម៉ៃភាគខាងត្បូង។ តំបន់នោះគ្របដណ្តប់លើតំបន់អភិរក្សជីវៈចម្រុះកែវសីម៉ា និងភ្នំណាមលៀរ។

ក- តំបន់នេះ គឺជាតំបន់មួយក្នុងចំណោមតំបន់ដែលមានតែ៦ប៉ុណ្ណោះនៅក្នុងតំបន់អាណាម៉ៃភាគខាងត្បូង។

ខ- ហើយវាក៏ជាផ្នែកតែមួយនៃតំបន់អេកូឡូស៊ីនៅក្នុងប្រទេសកម្ពុជា។

គ- ប្រហែលតំបន់នេះជាទីជម្រកដែលធំជាងគេនៅក្នុងតំបន់អាណាម៉ៃភាគខាងត្បូងនេះ។

ឃ- យោងទៅលើផែនទី ទំហំតំបន់មានអត្រាខ្ពស់ដែលអ្នកវិទ្យាសាស្ត្រអភិរក្សទាំងនោះបានសង្ស័យថានឹងមានទិន្នន័យច្រើនទៀតដែលត្រូវចុះសិក្សាស្រាវជ្រាវបន្ថែម។

ង- តាមការសិក្សាចាប់តាំងពីឆ្នាំ២០០០ បានបញ្ជាក់ថាភាពសំខាន់ៗរបស់សារព័ន្ធប្រភេទត្រូវរកឃើញមានវត្តមានរស់នៅក្នុងតំបន់ទាំងនោះ។

ដូច្នេះការគូសបញ្ជាក់អំពីការសិក្សាព្រៃស្រោងនៅក្នុងតំបន់អភិរក្សជីវចម្រុះកែវសីម៉ា និងតំបន់ភ្នំណាមលៀរ គឺជាតំបន់ដែលមានអទិភាពសំខាន់ជាងគេនៅក្នុងការអភិរក្សមហាតំបន់អាណាម៉ៃនេះ។

ឧបសម្ព័ន្ធពន្យល់អំពីបញ្ហាបច្ចេកទេសរបស់លោក Baltzer et al.(2002) មានបញ្ចូលពត៌មានលំអិត ហើយទិន្នន័យទទួលបានពីការស្រាវជ្រាវថ្មីៗត្រូវបានប្រមូល និងបញ្ចូលទៅក្នុងឧបសម្ព័ន្ធនេះតាំងពីឆ្នាំ២០០២កន្លងមក។

សេចក្តីសង្ខេបអំពីសារៈសំខាន់នៃតំបន់អេកូឡូស៊ីនៃព្រៃស្ងួតក្នុងតំបន់ទំនាបភាគខាងក្រោមទន្លេមេគង្គមានដូចខាងក្រោម ៖

## លក្ខណៈភូមិសាស្ត្រ



© WCS/E Pollard

អណ្តើកក្របីក្បាលលឿង

ក- ជាតំបន់មានផ្ទៃរាប ឬជាខ្ពង់រាបដែលមានផ្ទៃរាបស្មើនៃរយៈកំពស់ពី ៥០ ទៅ២០០ម៉ែត្រ។

ខ- មានជួរភ្នំអាណាម៉ៃ និងជួរភ្នំក្រវាញដែលទទួលរងទឹកភ្លៀងច្រើន។

គ-មានទីជម្រកដែលធ្លាប់លាតសន្ធឹងពីប្រទេសវៀតណាមដល់ភូមាត្រូវរងការបំផ្លាញស្ទើតែទាំងអស់ ប៉ុន្តែអ្វីដែលនៅសេសសល់នោះគឺមានវត្តមាននៅក្នុងប្រទេសកម្ពុជា។

## ជីវសាស្ត្រ

ក- តំបន់ព្រៃឈើមានភាគច្រើនជាតំបន់ព្រៃល្បោះដែលមានប្រភេទឈើខ្លុង និងត្បែងភាគច្រើន។

ខ- មានតំបន់ព្រៃពាក់កណ្ដាលស្រោងជាដុំៗដែលមានសារៈសំខាន់ចំពោះប្រភេទព្រៃឈើស្ងួតពឹងពាក់ ឬមានវត្តមានរស់នៅជាមួយទៅតាមរដូវកាល។

គ- មានតំបន់ដីសើម និងត្រពាំងច្រើនសម្រាប់ប្រភេទសត្វកម្រៗជាច្រើនរស់នៅ និងរកចំណី។

ឃ- មានដងស្ទឹងដ៏វែងឆ្លងកាត់តំបន់ព្រៃក្នុងខេត្តមណ្ឌលគិរីដែលកម្រឃើញមាននៅតំបន់ខ្ពង់រាបដទៃទៀតដូចជា ទន្លេមេគង្គ និងទន្លេស្រែពកដែលបានផ្គត់ផ្គង់ដល់វត្តមានរស់នៅរបស់ពពួកសត្វព្រៃ។

ង- ថ្វីត្បិតតែនៅភាគខាងក្រោមនៃតំបន់អេកូឡូស៊ីនេះមិនសូវសំបូរប្រភេទសត្វព្រៃដូចតំបន់ជួរភ្នំអាណាម៉ៃ ប៉ុន្តែតំបន់នេះមានប្រភេទកំពុងរងគ្រោះថ្នាក់ជាសាកលច្រើន ហើយដែលប្រភេទទាំងនោះមិនឃើញមានវត្តមានរស់នៅក្នុងទីជម្រកផ្សេងៗទៀតឡើយ។

ច- កត្តាសំខាន់បំផុតនៃតំបន់នេះគឺ ការប្រមូលផ្ដុំរស់នៅជាក្រុមរបស់ពពួកថនិកសត្វដូចជាពពួកគោសាទិស ឈ្លូស ប្រើស ដំរី និងពពួកមំសាសី ហើយដែលកត្តានេះគេធ្លាប់តែឃើញមាននៅភាគខាងកើតនៃតំបន់អាហ្វ្រិក ដែលចំនួនសត្វនៅទីនោះបានថយចុះអស់ជាច្រើនដោយសារតែការបរបាញ់។

ឆ- តំបន់នេះក៏មានវត្តមានប្រភេទសត្វស្លាបតំបន់ដីសើម ដែលកំពុងរងគ្រោះថ្នាក់ជាសាកលរស់នៅច្រើនដែរ។ រីឯពពួកក្ងោក និងប្រភេទសត្វត្មាតកម្រទាំងបីក៏មានវត្តមាននៅទីនេះដែរ។

ដូច្នេះខេត្តមណ្ឌលគិរី ស្ថិតនៅក្នុងតំបន់អេកូឡូស៊ីអាណាម៉ៃដែលមានសក្ដានុពលខ្ពស់សម្រាប់ការភិរក្សធនធានជីវចម្រុះព្រៃឈើ និងសត្វព្រៃគ្រប់ប្រភេទ។ ជាពិសេស ប្រសិនបើធៀបនឹងតំបន់អេកូឡូស៊ីទាំង ៥ (ជួរភ្នំក្រវាញ តំបន់វាលទំនាបភាគខាងកើតតំបន់ខ្ពង់រាបភាគខាងជើង តំបន់ខាងកើតទន្លេមេគង្គ និងទន្លេសាប) ខេត្តមណ្ឌលគិរី គឺជាខេត្តដែលមានធនធានធម្មជាតិសត្វព្រៃ និងព្រៃឈើ)សំបូរជាងគេ ព្រមទាំងមានផ្ទៃដីធំ និងទទួលសម្ពាធពីសកម្មភាពមនុស្សតិចជាងតំបន់ដទៃទៀត[៥] ។

## ១.៦ តំបន់មានសក្ដានុពលអភិរក្សសត្វខ្លាធំ

ខេត្តមណ្ឌលគិរីជាតំបន់អាទិភាពសំរាប់ជាទីជំរក និងការបង្កើតពូជរបស់ខ្លាធំ។ ខ្លាដំបង ឬខ្លាធំជាប្រភេទដែលពឹងផ្អែកលើការអភិរក្ស។ ពួកវាត្រូវការកិច្ចការពារពីការបរបាញ់ មានទីជម្រកគ្រប់គ្រាន់ និងរស់នៅចាប់សត្វដទៃទៀតធ្វើជាអាហារ។ នាពេលខ្លាធំមិនទាន់ត្រូវការកិច្ចអភិរក្ស ពួកវាជាប្រភេទចាប់សត្វដទៃទៀតយ៉ាងចំណាប់ជាងគេក្នុងចំណោមពួកស៊ីសាច់ជាអាហារ និង


© Chris Greenwood

ព្រៃល្បោះជ្រុះស្លឹកនៅរដូវក្ដៅ

[៥] (សូមអានឯកសារ ស្ដីពី Terrestrial Ecoregions of the Indo-Pacific, A Conservation Assessment, WWF ឆ្នាំ ២០០២ របស់ក្រុមលោក Eric Wikramanayake)។

បានបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការរក្សាលំនឹងមជ្ឈដ្ឋានមានជីវិតទាំងអស់នៅក្នុងធម្មជាតិ ប៉ុន្តែការបរបាញ់ទាក់ចាប់អស់ជាង២ទសវត្សកន្លងទៅនេះបានធ្វើឱ្យសារព័ន្ធចំនួនខ្លាធំថយចុះយ៉ាងខ្លាំងហើយការបាត់បង់នេះអាចហៅបានថា"ការវិនាសបាត់បង់អេកូឡូស៊ីធម្មជាតិនៃសត្វព្រៃ"។

អង្គការ និងអ្នកវិទ្យាសាស្ត្រខាងវិស័យអភិរក្សបានសិក្សាវាយតម្លៃទីជម្រកធម្មជាតិដែលមានវត្តមានសត្វខ្លា ធំរស់នៅ និងបានចាត់ថ្នាក់ទីជម្រករបស់វាសម្រាប់កំណត់អទិភាពអនុវត្តគម្រោងអភិរក្ស ។ ការសិក្សានេះផ្អែកលើមូលដ្ឋាន៧ចំណុចៈ **១**-បកស្រាយតាមផែនទីនូវទីជម្រកដែលមានសក្តានុពលសម្រាប់សត្វខ្លាធំ។ **២**-សិក្សាទិន្នន័យដែលទាក់ទងនឹងស្ថានភាព និងរបាយរស់នៅតាមភូមិសាស្ត្រដែលមានសត្វខ្លា។ **៣**-បង្កើតស្តង់ដារួមមួយសម្រាប់សិក្សាជីវសាស្ត្រ និងគុណភាពនៃដែនរស់នៅរបស់សត្វខ្លាធំ ។ **៤**-ការរុករានទីជម្រកខ្លាធំដោយសារសកម្មភាពមនុស្ស។ **៥**-បង្កើតប្រព័ន្ធស្វ័យប្រវត្តិសម្រាប់តាមដានការប្រែប្រួលដោយដែនជម្រកសត្វខ្លា។ **៦**-វិភាគកម្រិតអប្បបរមានៃតំបន់ដែលខ្លាធំអាចបង្កាត់ពូជ និង**៧**-កំណត់អទិភាពទៅលើការផ្លាស់ប្តូរស្ថានភាពអភិរក្ស។ លទ្ធផលនៃការសិក្សានេះមានចុះក្នុងសៀវភៅណែនាំបច្ចេកទេសស្តីពីការកំណត់អទិភាពសម្រាប់ការអភិរក្ស និងស្រាវជ្រាវខ្លាធំ ឆ្នាំ២០០៥-២០១៥។ តាមការបកស្រាយផែនទីដែនជម្រកសត្វខ្លាធំទាំងអស់មានជាង ៣.០០០កន្លែង។ ដែនជម្រកសម្រាប់ការអភិរក្សសត្វខ្លាធំសំខាន់ៗចំនួន៧៦ត្រូវបានកំណត់យកជាអទិភាពសម្រាប់ការអភិរក្សដែលក្នុងនោះជីវតំបន់ឥណ្ឌូចិនមាន ២០កន្លែង។

ជីវតំបន់ឥណ្ឌូចិននេះមានតំបន់ជួរភ្នំ Tenasserim តាមព្រំដែន ប្រទេសភូមា ថៃ និងតំបន់ជួរភ្នំអាណាម៉ែនៃប្រទេសឡាវ និងវៀតណាម ដែលជាតំបន់មាសក្តានុពលខ្ពស់សម្រាប់ការរស់នៅសត្វខ្លាធំ ។ ដោយឡែកតំបន់ព្រៃល្បោះជ្រុះស្លឹកនៅក្នុងប្រទេសកម្ពុជា ខេត្តមណ្ឌលគីរី) គឺជាតំបន់ល្អប្រសើរជាងគេបំផុតសម្រាប់ការរស់នៅនៃសត្វខ្លាធំ (មើលផែនទីលេខ២)។ តំបន់ព្រៃក្នុងខេត្តមណ្ឌលគីរី ត្រូវបានចាត់ចូលក្នុងចំណាត់ថ្នាក់ទី១ ដែលជាចំណាត់ខ្ពស់ល្អជាងគេសម្រាប់បង្ហាញថាមានវត្តមានខ្លាធំយ៉ាងតិចចំនួន ១០០ក្បាលកំពុងរស់នៅ មានភស្តុតាងបញ្ជាក់ថាខ្លាធំបង្កាត់ពូជ



© WCS

ខ្លាធំ ថតដោយម៉ាស៊ីនស្វ័យប្រវត្តិ ខេត្តមណ្ឌលគីរីមានសារៈសំខាន់ខ្លាំង ក្នុងការអភិរក្សសត្វខ្លាធំ

## តំបន់ខ្ពង់រាបសំខាន់សម្រាប់អភិរក្សសត្វខ្លាដំបង ឬ ខ្លាធំ





© WCS

សត្វក្រៀល និងសំបុកនៅក្នុងវាលព្រៃល្បោះ

កើតកូននៅក្នុងតំបន់នេះមានការគំរាមកំហែងតិចតួច និងមានគម្រោងអភិរក្សកំពុងតែអនុវត្តបានល្អ និងទទួលជោគជ័យនៅក្នុងតំបន់នេះ ដូចជាគម្រោងអភិរក្សជីវចម្រុះ-សីម៉ានៅស្រុកកែវសីម៉ា និងគម្រោងអភិរក្សព្រៃការពារក្នុងស្រុកកោះញែកនៅខេត្តមណ្ឌលគិរីជាដើម។

ទោះបីជាសារព័ន្ធចំនួនខ្លាធំនៅខេត្តមណ្ឌលគិរីនេះមិនត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃចំណាត់ថ្នាក់ទី១ខាងលើនេះក៏ដោយ ក៏ទីជម្រកព្រៃធម្មជាតិសម្រាប់សត្វខ្លាធំរស់នៅបង្កើតកូនមានលក្ខណៈសមស្របល្អបំផុត បើធៀបទៅនឹងទីជម្រករស់នៅនៃតំបន់ដទៃទៀត។ ដូច្នេះខេត្តមណ្ឌលគិរីមានលក្ខណៈសម្បត្តិច្រើនក្នុងការទាក់ទាញគម្រោងអភិរក្សព្រៃឈើ និងប្រភេទសត្វព្រៃសំខាន់ៗ[៦]។



© Fletcher & Baylis / WWF-Cambodia

ស្វាកន្ទុយស

[៦] (សូមអានអត្ថបទណែនាំរបស់អង្គការ WWF, WCS ស្ដីពី Setting Priorities for the Conservation and Recovery of Wild Tigers: 2005-2015, ***A user's guide*** ឆ្នាំ ២០០៦)។


តំបន់អាទិភាពនៃជីវចម្រុះនៅខេត្តមណ្ឌលគិរី
0 25 50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA/MaFF, DoG/MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16° N)
Unit: Meter
Vietnam
Lao PRD
Thailand
Cambodia

## ២. ខេត្តមណ្ឌលគិរីៈតំបន់ដែលមានសារៈសំខាន់សម្រាប់ជីវសាស្ត្រ និងតំបន់អភិរក្សសំខាន់ៗ


© WCS

ដំរី (អាស៊ី) ខេត្តមណ្ឌលគិរីមានសារសំខាន់ក្នុងការអភិរក្សដំរី


© R Kanjanavanit

ពពូលក្បាលព្រលែត

នៅក្នុងផ្នែកទីមួយខាងលើបានបង្ហាញអំពីកម្មវិធីអភិរក្សអន្តរជាតិដោយបានកំនត់បញ្ជាក់អំពីសារៈសំខាន់ដោយបានរួមបញ្ចូលផ្នែកខាងកើតនៃប្រទេសកម្ពុជាជាពិសេសខេត្តមណ្ឌលគិរី ដែលមានជីវៈចំរុះជាច្រើនរស់នៅក្នុងខេត្តនេះផងដែរ។ ប៉ុន្តែលទ្ធផលនៃការសិក្សាខាងលើពុំមានបញ្ជាក់លំអិតអំពីសមាសភាពនៃជីវចម្រុះដើម្បីជួយដល់ស្ថាប័នរដ្ឋាភិបាល និងអ្នកអភិរក្សទាំងឡាយក្នុងការកំណត់ថាតើតំបន់មួយណាដែលមានសារៈសំខាន់បំផុតនោះទេ ព្រោះតំបន់ខ្លះនៃខេត្តមណ្ឌលគិរីមានសារៈសំខាន់ផ្នែកជីវៈចំរុះជាងតំបន់ខ្លះទៀតនៅក្នុងខេត្តនេះ។

ការសិក្សាវិភាគទិន្នន័យប្រមូលបាន និងការចុះអង្កេតផ្ទាល់នៅលើភូមិសាស្ត្រដោយក្រុមជំនាញការជាតិ និងអន្តរជាតិបានកំណត់នូវតំបន់សំខាន់បំផុតសម្រាប់អភិរក្សជីវចម្រុះក្នុងខេត្តមណ្ឌលគិរី។ តាមរយៈការអភិរក្សតំបន់ទាំងនេះខេត្តមណ្ឌលគិរីអាចតំណាងឱ្យប្រទេសកម្ពុជាក្នុងការថែរក្សាការពារតំបន់ជីវចម្រុះ ដែលមានសារៈសំខាន់ជាសាកលទាំងឡាយ។ យើងបានប្រើពត៏មានបីដើម្បីកំនត់តំបន់សំខាន់ៗសំរាប់ធ្វើការអភិរក្សជីវៈចំរុះ ដូចជាសម្រង់ពត៏មានស្តីពីតំបន់អទិភាពសំខាន់ៗក្នុងចំណោមតំបន់អេកូឡូស៊ីទាំង២០០នៅលើផែនដី សម្រង់ពត៏មានស្តីពីតំបន់សម្រាប់ជីវចម្រុះសំខាន់ៗឬតំបន់សត្វស្លាបសំខាន់ និងសម្រង់ពត៏មានស្តីពីសំណើរក្រុមសម្រាប់អភិរក្សដំរី។ តាមរយៈការការពារតំបន់ធំៗក្នុងចំណោមតំបន់ទាំងបីនេះជីវចម្រុះក្នុងខេត្តមណ្ឌលគិរី ក៏ត្រូវបានថែរក្សាការពារ។

### ២.១ តំបន់អទិភាពអេកូឡូស៊ីនៃព្រៃល្បោះទន្លេមេគង្គក្រោម

អ្នកវិទ្យាសាស្ត្រកម្ពុជា និងអន្តរជាតិចំនួន៣០រូបបានសហការគ្នាធ្វើការកំនត់ផ្នែកសំខាន់បំផុតនៃតំបន់អេកូឡូស៊ីព្រៃល្បោះទន្លេមេគង្គភាគខាងក្រោម។ ពួកគេបានវិភាគពត៏មានតាមរយៈរបាយ(focal taxa) ។ បណ្តាប្រភេទសត្វទាំងនេះអាចមានសារៈសំខាន់សំរាប់អភិរក្សសកលរឺមួយក៏តំណាងអោយប្រភេទព្រៃល្បោះតំបន់ស្ងួត។ តាមរយៈការវិភាគរួមបញ្ចូលគ្នានៃប្រភេទប្រជាសាស្ត្រដែលស្គាល់នោះមានតំបន់អាទិភាពចំនួន៩កន្លែងត្រូវបានកំណត់ហើយដែលនៅក្នុងនោះមានតំបន់៣កន្លែង ដែលមានផ្ទៃដីទាំងមូល រឺផ្នែកខ្លះស្ថិតនៅក្នុងខេត្តមណ្ឌលគិរីដូចជា:

- *ភាគខាងលើនៃទន្លេស្រែពកៈ* មានតំបន់ភាគកណ្តាល និងភាគខាងកើតនៃខេត្តមណ្ឌលគិរី ។ តំបន់នេះគឺមានសារៈសំខាន់ជាពិសេសចំពោះប្រភេទគោសាទិសព្រៃ ក្នុងនោះរួមមានក្របីព្រៃរមាំង ត្រកួលខ្វា ពពួកសត្វស្លាបធំៗ និងក្រពើដែលមានសារព័ន្ធរស់នៅច្រើន និងចុងក្រោយគេបង្អស់នៃពិភពលោក។
- *តំបន់ភ្នំព្រិចៈ* គឺភាគកណ្តាល និងខាងលិចនៃខេត្តមណ្ឌលគិរី។ តំបន់នេះជាជម្រករស់នៅនៃ


តំបន់ជីវចំរុះសំខាន់នៅខេត្តមណ្ឌលគិរី
0
25
50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA\MaFF, DoG\MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16° N)
Unit: Meter
ទីតាំងស្រុក
ផ្លូវ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ផ្លូវទឹក
តំបន់ជីវចំរុះសំខាន់
Vietnam
Lao PRD
Thailand
Cambodia
តំបន់លំផាត់
តំបន់ភាគខាងលើទន្លេស្រែពក
តំបន់ទំនាបខេត្តក្រចេះ-មណ្ឌលគិរី
តំបន់
ស្នួល
កែវសីមា
អូររាំង
ទន្លេស្រែពក
ទន្លេមេគង្គ
ទន្លេសេសាន
អូរគ្រៀង
អូរទេ
ស្ទឹងត្រែង
សេសាន
សៀមបូក
សំបូរ
ក្រចេះ
ព្រែកប្រសព្វ
ស្នួល
អូររាំង
កែវសីមា
សែនមនោរម្យ
ពេជ្រាដា
កោះញែក
លំផាត់
អូរយ៉ាដាវ
600000
620000
640000
660000
680000
700000
720000
740000
760000
780000
1500000
1480000
1460000
1440000
1420000
1400000
1380000
1360000
1340000



© WCS

ត្មាតត្នោត មានទីតាំងតិចតួចបំផុតដែលជាកន្លែងធ្វើសំបុក នៅលើពិភពលោក នេះជាសំបុកនៅក្នុងខេត្តមណ្ឌលគិរី

ហ្វូងដំរីហ្វូងគោសាទិស និងជាតំបន់សំខាន់សម្រាប់ហ្វូងពានរជាពិសេសពួកស្វាកន្ទុយស ឬស្វាក្រវ៉ាត់។

- *ភាគខាងក្រោមទន្លេស្រែពក:* គឺជានៃផ្នែកទន្លេស្រែពកដែលហូរកាត់ភាគខាងជើងមណ្ឌលគិរី និងចាក់ចូលទៅខេត្តរតនគិរី។ តំបន់នេះមានសារៈសំខាន់ជាពិសេសចំពោះពពួកស្វាបទឹក ពពួកឧរង្គសត្វ និងសត្វស្វាបប្រភេទខ្ទប់ដីមេគង្គលើ (Mekong Wagtails - *Motacilla samveasnae*).

## ២.២ តំបន់ជំរាលភាគខាងលិចនៃជួរភ្នំអាណាម៉ែភាគខាងត្បូង

ការវិភាគលំអិតនៃមហាតំបន់ជួរភ្នំអាណាម៉ែមិនទាន់បានសិក្សានៅឡើយ ។ ទោះបីជាមិនទាន់មានពត៌មានលំអិតក៏ដោយ ក៏ក្រុមអ្នកវិទ្យាសាស្ត្រជាង៨០នាក់បានកំណត់តំបន់សំខាន់ៗចំនួន២៦ នៅក្នុងការសិក្សានៃតំបន់ព្រៃឈើនៅក្នុងសារព័ន្ធអេកូឡូស៊ីភាគខាងក្រោមទន្លេមេគង្គ ។ បន្ថែមលើការសិក្សាព្រៃល្បោះក្នុងតំបន់ជួរភ្នំ អាណាម៉ែភាគខាត្បូងមានតំបន់សំខាន់មួយទៀត គឺតំបន់ជំរាលភាគខាងត្បូងត្រូវបានកំណត់ជាតំបន់អាទិភាពសម្រាប់អភិរក្ស ។ តំបន់នេះគ្របដណ្តប់ទៅដោយព្រៃស្រោង និងពាក់កណ្តាលស្រោងនៅតាមតំបន់ជួរភ្នំនៃព្រំដែនវៀតណាម ពីស្រុកសែនមនោរម្យរហូតដល់ស្រុកស្នួល។ តំបន់នេះមានសំណើមខ្ពស់ជាងតំបន់ដទៃទៀតក្នុងខេត្តមណ្ឌលគិរី ហើយតំបន់ព្រៃល្បោះនេះមានសារៈសំខាន់សម្រាប់ក្រុមប្រភេទសត្វផ្សេងៗទៀត ដែលបានរកឃើញនៅក្នុងតំបន់ព្រៃល្បោះស្ងួត ។ តំបន់នេះមានសារៈសំខាន់ជាពិសេសចំពោះសត្វខ្លាដំបង ពួកគោសាទិស ដំរីពានរ និងសត្វស្លាប ដែលរកចំណីនៅលើដីមួយចំនួន។ តំបន់នេះប្រហែលជាទីជម្រកមួយនៃពិភពលោកសម្រាប់របាយរស់នៅដ៏ច្រើននៃសារព័ន្ធប្រភេទស្វាក្រវ៉ាត់ និងទោចថ្គាល់លឿង ។ ព្រៃឈើនៃតំបន់នេះមានសារៈសំខាន់ជាសាកលសម្រាប់ការរស់នៅរបស់សារព័ន្ធប្រភេទក្ងោក និងទទាទ្រូងលឿងនៅក្នុងប្រទេសកម្ពុជា។



© Allan Michaud

ដំរីឈ្មោលក្នុងរណ្តៅទឹក



© WCS/E Pollard

ពង្រួល



តំបន់សំខាន់បំផុតរបស់សត្វដំរី
នៅខេត្តមណ្ឌលគិរី
0 25 50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA\MaFF, DoG\MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16º N)
Unit: Meter
ទីតាំងស្រុក
ផ្លូវ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ផ្លូវទឹក
តំបន់សំខាន់បំផុតរបស់សត្វដំរី
Vietnam
Lao PRD
Thailand
Cambodia



© WCS/E Pollard

វាលខ្ពង់រាបខេត្តមណ្ឌលគិរី

## ២.៣ តំបន់សត្វស្លាបទឹកសំខាន់ៗ

តំបន់សត្វស្លាបសំខាន់ៗចំនួន៤កន្លែងត្រូវបានរកឃើញនៅក្នុងខេត្តមណ្ឌលគិរីនេះ ព្រមទាំងបានកំណត់ថាជាតំបន់ដែលមានពពួកបក្សីរស់នៅច្រើន ឬជាតំបន់ដែលមានសត្វស្លាបកំពុងរងគ្រោះថ្នាក់រស់នៅច្រើន ដូច្នេះតំបន់ទាំងនេះមានសារៈសំខាន់ខ្លាំងចំពោះការអភិរក្ស។

ភាគខាងជើងនៃខេត្តមានតំបន់សត្វស្លាបសំខាន់លេខ KH ០២៧ ស្ថិតនៅក្នុងស្រុកស្នួល ស្រុកកែវសីម៉ា និងស្រុកអូរាំងដែលមានសារៈសំខាន់សម្រាប់ការអភិរក្សប្រភេទទទាទ្រូងលឿង ស្ដេចក្ងូលីត ក្ងោក ទាព្រៃស្លាបស និងកេងកងធំក្នុងចំណោមប្រភេទសត្វស្លាបទាំងអស់។ ភាគកណ្ដាល និងតំបន់ខាងលិចនៃខេត្តនេះមានតំបន់សត្វស្លាបសំខាន់លេខ KH ០២៦ ជាវាលទំនាបស្ថិតក្នុងខេត្តក្រចេះ និងមណ្ឌលគិរីដែលមានសារៈសំខាន់សម្រាប់ប្រភេទត្មាត ក្ងយក្ស ក្រៀល និងពពួកក្ងោក ។ ប្លុកខាងកើតនៃព្រៃល្បោះមានតំបន់សត្វស្លាបសំខាន់លេខ KH ០២៥ ស្ថិតនៅភាគខាងលើនៃទន្លេស្រែពកដែលត្រូវបានក្រុមអ្នកអភិរក្សធ្វើរបាយការណ៍ថាជាតំបន់សំខាន់មួយដែលតំណាងឱ្យសហគមន៍សត្វស្លាបទាំងអស់នៃព្រៃល្បោះទាំងអស់នៅភាគកណ្ដាលឧបទ្វីបឥណ្ឌូចិន។ ផ្នែកនៃតំបន់សត្វស្លាបសំខាន់លេខ KH ០២៤ គឺលំផាត់ដែលស្ថិតនៅភាគខាងជើងនៃខេត្តមណ្ឌលគិរី។ តំបន់នេះមានសារសំខាន់សម្រាប់ពពួកសត្វស្លាបដែលចូលចិត្តរកស៊ី និងរស់នៅតាមមាត់ទន្លេ និងប្រភេទសត្វស្លាបទឹកជាច្រើនទៀត។



© WWF Cambodia

ព្រៃល្បោះចំរុះ

## ២.៤ តំបន់សម្រាប់ការអភិរក្សសត្វដំរី

ការព្យាយាមវិនិច្ឆ័យតំបន់ដែលមានសារៈសំខាន់សម្រាប់ការអភិរក្សដំរីនៅក្នុងដែនព្រៃឈើខេត្តមណ្ឌលគិរីកំពុងត្រូវបានលើកយកមកសិក្សា។ ស្ថិតក្នុងដំណើរការនេះ ជំនាញការបានអង្កេតលើកំណត់ត្រានានាទាក់ទងនឹងសត្វដំរីនៅកម្ពុជា និងបានជ្រើសរើសយកតំបន់នៃខេត្តមណ្ឌលគិរី ពីដែនស្រុកកែវសីម៉ារហូតដល់ស្រុកកោះញែក និងតំបន់ខ្លះនៅក្នុងព្រំដែនវៀតណាមដែលមានសារៈសំខាន់ខ្លាំងចំពោះការអភិរក្សដំរីទាំងនៅក្នុងប្រទេសកម្ពុជា និងចំពោះការអភិរក្សថ្នាក់អន្តរជាតិ។

## ២.៥ ការកំនត់តំបន់សំខាន់ៗនៃជីវចម្រុះនៅក្នុងខេត្តមណ្ឌលគិរីផ្អែកលើទិន្នន័យនៃការសិក្សា

ដើម្បីកំណត់តំបន់សំខាន់បំផុតនៃខេត្តមណ្ឌលគិរីទិន្នន័យទាំងនេះត្រូវបានប្រៀបធៀប និងបញ្ចូលទៅក្នុងប្រព័ន្ធផែនទីតាមម៉ាស៊ីនកុំព្យូទ័រ។ បើតំបន់បីដែលត្រួត



© WWF Cambodia

ទន្សោង ប្រភេទមួយក្នុងចំណោមប្រភេទ៣ផ្សេងទៀត នៃអំបូរគោសាទិស ដែលមានវត្តមានក្នុងខេត្តមណ្ឌលគិរី


ការកំណត់តំបន់ជីវចម្រុះនៅខេត្តមណ្ឌលគិរី
0
25
50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA\MaFF, DoG\MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16° N)
Unit: Meter
ចំណាត់ថ្នាក់នៃជីវចម្រុះ
ទីតាំងស្រុក
ផ្លូវ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ផ្លូវទឹក
សំខាន់បំផុត
សំខាន់បង្គួរ
សក្កានុពលខ្ពស់ ប៉ុន្តែត្រូវការសិក្សាបន្ថែម
សំខាន់ទាបបំផុត
Vietnam
Lao PRD
Thailand
Cambodia
600000
620000
640000
660000
680000
700000
720000
740000
760000
780000
1340000
1360000
1380000
1400000
1420000
1440000
1460000
1480000
1500000
ទន្លេស្រែពក
ពេជ្រាដា
កោះញែក
អូររាំង
សែនមនោរម្យ
កែវសីមា
ពេជ្រចិន្ដា
ក្រចេះ
ស្នួល

ត្លាត្រូវបានកំណត់ជាតំបន់ដែលមានអទិភាពខ្ពស់ជាង គេបន្ទាប់ពីការពិគ្រោះយោបល់តាមការបញ្ចូលតំបន់បន្ថែមរួចមក ។ ទីតាំងតំបន់ទាំងនេះស្ថិតនៅឆ្ងាយភាគខាងជើងឈៀងខាងកើតនៃខេត្ត ព្រមទាំងមានសំបុកសត្វត្លាតផេះដែលជាប្រភេទកំពុងរងគ្រោះថ្នាក់ជិតផុតពូជបំផុត។ ទីតាំងសំបុកត្លាតផេះនេះ គឺជាទីតាំងសំបុកមួយក្នុងចំនោមសំបុកខ្លះៗដែលគេធ្លាប់បានដឹងយ៉ាងតិចតួចបំផុតនៅលើពិភពលោក ។

គួរកត់សម្គាល់ថាការវិភាគនេះមិនបានរាប់បញ្ចូលនូវតម្លៃនៃជីវភាពរបស់ប្រជាជនទេ គឺវាផ្អែកទាំងស្រុងទៅលើសារៈសំខាន់នៃជីវចម្រុះតែមួយផ្នែកប៉ុណ្ណោះ។ ផ្អែកទៅតាមការវិភាគ គេបានធ្វើការបែងចែកកម្រិតសំខាន់នៃជីវៈចំរុះក្នុងខេត្តទាំងមូលជាបួនៈ

### តំបន់សំខាន់បំផុត

ជាតំបន់ដែលមានលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមៈ

ក- ទ្រទ្រង់ដល់គ្រប់ប្រភេទសត្វសំខាន់ៗដែលខុសគ្នាជាច្រើន ។

ខ- ទ្រទ្រង់ដង់ស៊ីតេខ្ពស់នៃសារព័ន្ធប្រភេទសត្វសំខាន់ៗមួយចំនួន ។

គ- តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ធ្វើឱ្យប្រភេទសត្វសំខាន់មួយចំនួនកើនឡើង ។

ឃ- តំបន់បង្កើតបានជាច្រកសម្រាប់ប្រភេទសត្វសំខាន់ៗចល័តចេញ និងចូល ។

ង- មានប្រភេទទីជម្រកជាពិសេសដែលកម្ររកបាន ដូចនេះគេគួរតែធ្វើការអភិរក្សតំបន់ដែលមានលក្ខណៈសំខាន់ទាំងនេះ ដើម្បីការពារតម្លៃជីវៈចម្រុះពេញលេញជាអន្តរជាតិនៃខេត្តមណ្ឌលគិរី ហើយតំបន់ទាំងនេះគួរតែត្រូវបានចាត់វិធានការពារដ៏តឹងរឹង ។

### តំបន់សំខាន់មធ្យម

ជាតំបន់ដែលមានៈ

ក- ទ្រទ្រង់ដល់ប្រភេទសត្វសំខាន់ផ្សេងៗគ្នាមួយចំនួនតាមដង់ស៊ីតេបង្គួរនៃសារព័ន្ធរបស់វា ឬ

ខ- បង្កើតបានជាតំបន់ទ្រនាប់សម្រាប់តំបន់ដែលមានសារៈសំខាន់បំផុត។

គួរតែធ្វើការអភិរក្សតំបន់ ដែលមានលក្ខណៈសំខាន់ទាំងនេះ ដើម្បីការពារជីវចម្រុះនៃខេត្តមណ្ឌលគិរីឱ្យមានតម្លៃពេញលេញជាសាកល។ ប៉ុន្តែតំបន់ទាំងមានការប៉ះពាល់តិចតួច និងមានជំរើសច្រើនយ៉ាងទាក់ទងទៅនឹងការគ្រប់គ្រង។

### តំបន់សំខាន់តិចតួច

ជាតំបន់ដែលមិនទ្រទ្រង់ដល់ប្រភេទសត្វសំខាន់ណាមួយឡើយ ឬគ្រាន់តែមានសារព័ន្ធនៃប្រភេទសត្វសំខាន់ដែលមានចំនួនតិចតួច។ តំបន់ទាំងនេះប្រហែលជាមិនសំខាន់ចំពោះការអភិរក្សលើតម្លៃជីវចម្រុះជាសាកលរបស់ខេត្តនោះទេ ទោះបីជាតំបន់ខ្លះស្ថិតនៅក្នុងតំបន់សំខាន់ដែលមានតម្លៃក្នុងមូលដ្ឋានខ្ពស់ក៏ដោយ។

### តំបន់មានសក្តានុពលខ្ពស់ប៉ុន្តែតម្រូវឱ្យមានការសិក្សា

តំបន់នេះត្រូវបានគេសង្ស័យថាជាតំបន់សំខាន់មធ្យម ឬសំខាន់បំផុត ប៉ុន្តែមានការសិក្សាមិនទាន់គ្រប់គ្រាន់សម្រាប់ធ្វើការវាយតម្លៃនូវភាពសំខាន់របស់វានៅឡើយ។

## ២.៦ ស្ថានភាពតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃ

ខេត្តមណ្ឌលគិរីមានតំបន់ព្រៃការពារចំនួន៥កន្លែង រួមមានដែនជម្រកសត្វព្រៃភ្នំព្រិច ភ្នំណាមលៀរ លំផាត់ តំបន់ព្រៃការពារមណ្ឌលគិរី និងតំបន់អភិរក្សជីវចម្រុះសីម៉ា ដែលត្រូវបានបង្កើតឡើងតាមរយៈការចេញជាព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធដទៃទៀត។ តំបន់ព្រៃការពារទាំងនេះរួមមានៈ



បណ្តុំតំបន់ការពារនៅខេត្តមណ្ឌលគិរី
0
25
50
Kilometers
Prepared by GIS Specialist, WWF Cambodia
April 2008
Data sources: FA\MaFF, DoG\MLMUPC
Coordinate System Use:
Projection: UTM
Zone: 48N
Ellipsoid: Everest 1830
Datum: Indian 1960 (Vietnam near 16º N)
Unit: Meter
ទីតាំងស្រុក
ផ្លូវ
ព្រំប្រទល់ប្រទេស
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ផ្លូវទឹក
តំបន់គ្រប់គ្រង
ក្រសួងបរិស្ថាន
ក្រសួងកសិកម្ម
Vietnam
Lao PRD
Thailand
Cambodia
ដែនជំរកសត្វព្រៃលំផាត់
ដែនជំរកសត្វព្រៃភ្នំព្រេច
ដែនជំរកសត្វព្រៃស្នួល
ដែនជំរកសត្វព្រៃភ្នំណាំល្មៀ
ព្រៃការពារមណ្ឌលគិរី
តំបន់អភិរក្សជីវចំរុះសីមា
ទន្លេស្រែពក
ទន្លេសេសាន
ទន្លេមេគង្គ
អូរគ្រៀង
អូរទេ
អូរឆ្លូង
កោះញែក
កែវសីមា
ពេជ្រាដា
សែនមនោរម្យ
អូររាំង
ស្នួល
ក្រចេះ
ព្រែកប្រសព្វ
ឆ្លូង
សំបូរ
ស្ទឹងត្រែង
សេសាន
សៀមបូក
សៀមប៉ាង
លំផាត់
កូនមុំ
អូរយ៉ាដាវ
600000
620000
640000
660000
680000
700000
720000
740000
760000
780000
1340000
1360000
1380000
1400000
1420000
1440000
1460000
1480000
1500000



© Allan Michaud

ស្វាព្រាម



© WCS/E Pollard

កង្កែប ប្រភេទមួយដែលមានដោយសំបូរក្នុងខេត្តមណ្ឌលគិរី

ឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងសង្គម ការកាត់បន្ថយភាពក្រីក្រ និងសំណើរសុំរបស់អភិបាលខេត្តមណ្ឌលគិរី រាជរដ្ឋាភិបាលបានសម្រេច



© WCS

ខ្លារខិន

កាត់ផ្ទៃដីមួយចំនួនចេញពីដែនជម្រកសត្វព្រៃស្នួលភ្នំណាមលៀរ និងតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ “មណ្ឌលគិរី” ដែលមានទំហំផ្ទៃដីសរុប៧១.៨៩២ហិកតា សម្រាប់ការអភិវឌ្ឍរបស់ខេត្តមណ្ឌលគិរី និង ការបែងចែកដោយសមធម៌ជូនប្រជាពលរដ្ឋដែលខ្វះខាតដីបង្កបង្កើនផលជាក់ស្តែង។ (លិខិតលេខ៥៧៩សជណ.កស ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ២០០៧របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ១១៨៧ សណ.បស្ល.កអធ ចុះថ្ងៃទី១៥ ខែញ្ញា ឆ្នាំ២០០៦ របស់ក្រសួងបរិស្ថាន) ។ ខាងក្រោមជាផ្ទៃដីដែលបានកាត់ចេញៈ

តារាងទី៤: ផ្ទៃដីដែលបានកាត់ចេញពីតំបន់សម្រាប់ អភិរក្សព្រៃឈើ និងសត្វព្រៃក្នុងខេត្តមណ្ឌលគិរី

| ល.រ | ប្រភេទតំបន់ | ឈ្មោះ | លិខិតគតិយុត្ត | ចុះកាលបរិច្ឆេទ | ទំហំកាត់ចេញ (ហ.ត) | នៅសល់ (ហ.ត) |
|---|---|---|---|---|---|---|
| ១ | ដែនជម្រកសត្វព្រៃ | ណាមលៀរ | ព្រះរាជក្រឹត្យ | ០១-១១-៩៣ | ២.៧០៥ | ៤៤.៧៩៥ |
| ២ | ព្រៃការពារ | មណ្ឌលគិរី | អនុក្រឹត្យ | ៣០-០៧-០២ | ៥៦.៤៦៧ | ៣៧២.៩៧១ |
| | សរុប | | | | ៥៩.១៧២ | ៤១៧.៧៦៦ |

តារាងទី៩: តំបន់សម្រាប់អភិរក្សព្រៃឈើនិងសត្វព្រៃ ក្នុងខេត្តមណ្ឌលគិរី

| ល.រ | ប្រភេទតំបន់ | ឈ្មោះ | លិខិតគតិយុត្ត | ចុះកាលបរិច្ឆេទ | (ទំហំហ.ត) | ទីតាំង |
|---|---|---|---|---|---|---|
| ១ | ដែនជម្រកសត្វព្រៃ | ភ្នំព្រេច | ព្រះរាជក្រឹត្យ | ០១-១១-៩៣ | ២២២.៥០០ | ស្រុកកែវសីម៉ា |
| ២ | ដែនជម្រកសត្វព្រៃ | ណាមលៀរ | ព្រះរាជក្រឹត្យ | ០១-១១-៩៣ | ៤៧.៥០០ | ស្រុកពេជ្រដា |
| ៣ | ដែនជម្រកសត្វព្រៃ | លំផាត់ | ព្រះរាជក្រឹត្យ | ០១-១១-៩៣ | ២៥០.០០០ | ស្រុក លំផាត់ |
| ៤ | ព្រៃការពារ | មណ្ឌលគីរី | អនុក្រឹត្យ | ៣០-០៧-០២ | ៤២៩.៤៣៨ | ស្រុក កោះញែក |
| ៥ | តំបន់ អភិរក្សជីវចម្រុះ | សីម៉ា | សេចក្ដីប្រកាស ក្រសួងកសិកម្ម | ១២-០៨-០២ | ៣០៥.៤៤០ | ស្រុកកែវសីម៉ា |

ដូច្នេះ ផ្ទៃដីតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃនៅក្នុងខេត្តមណ្ឌលគិរីមានទំហំសរុប១.១៩៥.៧០៦ហិកតា

## ឈ. ការគ្រប់គ្រងតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃក្នុងខេត្តមណ្ឌលគិរី

ដូចគ្នានឹងតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃក្នុងបណ្ដាខេត្តមួយចំនួនរបស់ព្រះរាជាណាចក្រកម្ពុជាដែរ តំបន់ព្រៃការពារ និងតំបន់ធម្មជាតិទាំងអស់ក្នុងខេត្តមណ្ឌលគិរីត្រូវបានរាជរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការការពារ និងអភិរក្សទាំងព្រៃឈើ និងពពួកសត្វព្រៃគ្រប់ប្រភេទ ។ ទាំងនៅក្នុងប្រទេស និងការចូលរួមក្នុងការថែរក្សាការពារបរិស្ថានក្នុងតំបន់ រាជរដ្ឋាភិបាលកំពុងបន្តពង្រឹងការអនុវត្តច្បាប់ និងការអនុវត្តអនុសញ្ញាពាក់ព័ន្ធនានាដែលប្រទេសកម្ពុជាបានចូលរួមជាសមាជិកកន្លងមក។ ខាងក្រោមជាលិខិតបទដ្ឋានស្របច្បាប់មួយចំនួនដែលជាប់ពាក់ព័ន្ធនឹងការការពារ និងអភិរក្សជីវៈចម្រុះក្នុងខេត្តមណ្ឌលគិរី:

### អនុសញ្ញាស្ដីពី ជីវៈចម្រុះ

ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកអនុសញ្ញាស្ដីពី ជីវចម្រុះក្នុងឆ្នាំ១៩៩៥។ អនុសញ្ញានេះត្រូវបានប្រកាសឱ្យប្រើដូចច្បាប់ជាតិដែលកំពុងចូលធរមាននៅក្នុងប្រទេសកម្ពុជាតាមព្រះរាជក្រមលេខ នស/រកម/០៦០៦/០១២ ចុះថ្ងៃទី១៦ ខែមិថុនាឆ្នាំ២០០៦ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាស្ដីពីជីវចម្រុះ។ អនុសញ្ញានេះមានគោលបំណងអនុវត្តវិធានការអភិរក្សជីវចម្រុះរួមគ្នា និងគ្រប់គ្រងការប្រើប្រាស់ធនធានជីវចម្រុះឱ្យមាននិរន្តភាព។

### ច្បាប់ស្ដីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ:

ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ច្បាប់នេះមានគោលបំណងការពារគ្រប់គ្រងធនធានធម្មជាតិ និងវាយតម្លៃរាល់ផលប៉ះពាល់បរិស្ថានដែលក្នុងនោះមានទាំងការអភិរក្សធនធានជីវចម្រុះផងដែរ។

**ច្បាប់ ស្ដីពីព្រៃឈើ:** (ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០២) ព្រៃឈើ និងពពួកសត្វព្រៃគ្រប់ប្រភេទស្ថិតនៅក្រោមការគ្រប់គ្រង ការការពារ ស្រាវជ្រាវ និងអភិរក្សដោយរដ្ឋបាលព្រៃឈើ និងច្បាប់នេះ។

**ច្បាប់ ស្ដីពីជលផល:** (ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦) គ្រប់គ្រងធនធានជលផល និងអភិរក្សប្រកបដោយនិរន្តរភាព។

**ច្បាប់ ភូមិបាល:** (ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១) ។



© WCS/E Pollard

ទេសភាពពេលព្រឹកក្នុងខេត្តមណ្ឌលគិរី



© Eleanor Briggs

ការនេសាទជាលក្ខណៈគ្រួសារ ជាប្រពៃណីដ៏សំខាន់



© Eleanor Briggs

ព្រៃឈើមានសារសំខាន់ចំពោះជីវភាពគ្រួសារ ការប្រមូលជ័រ

ច្បាប់នេះមាន៨ជំពូក និង២៦៨មាត្រា។ រាល់ការចាត់ចែងគ្រប់គ្រងការផ្ដល់សិទ្ធិកាន់កាប់ និងការប្រើប្រាស់ដីធ្លីត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**ច្បាប់ស្ដីពី តំបន់ការពារធម្មជាតិ:** (ព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០០៨) ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងការអភិរក្សជីវចម្រុះ និងការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។

**ព្រះរាជក្រឹត្យ** ស្ដីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣: ក្នុងព្រះរាជក្រឹត្យនេះ តំបន់ការពារធម្មជាតិទាំងអស់មាន២៣កន្លែង ដែលមានដែនជម្រកសត្វភ្នំណាមលៀរ ភ្នំព្រិច និងលំផាត់ ស្ថិតក្នុងខេត្តមណ្ឌលគិរី។

អនុក្រឹត្យលេខ ៧៥អនក្រ.បក ស្ដីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ"មណ្ឌលគិរី" ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ២០០២។

អនុក្រឹត្យលេខ ២០៦អនក្រ.បក ស្ដីពី ការកាត់ផ្ទៃដីចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគិរី" ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧។

ប្រកាសលេខ ២៦០សប្រក.កសក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ ស្ដីពី តំបន់អភិរក្សជីវចម្រុះ "សីម៉ា" ក្នុងព្រៃសម្បទានក្រុមហ៊ុនសាមលីញអន្តរជាតិនៅខេត្តមណ្ឌលគិរី-ក្រចេះ។

# តារាងឧបសម្ព័ន្ធ ( Annex : List of Wildlife Species )
# ប្រភេទសត្វព្រៃសំខាន់ៗដែលត្រូវការអភិរក្សនៅក្នុងខេត្តមណ្ឌលគិរី

## ថនិកសត្វ

| ល.រ | ឈ្មោះ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះ(អង់គ្លេស) | ស្ថានភាពអភិរក្សជាសាកល | ស្ថានភាពអភិរក្សតាមច្បាប់ស្តីពីព្រៃឈើ | ស្ថានភាពការពារតាមអនុសញ្ញាសាយតេស | ប្រភេទអភិរក្សក្នុងតំបន់ព្រៃឡើងៈ |
|---|---|---|---|---|---|---|---|
| ១ | ពង្រូល | *Manis javanicatime* | Malayan Pangolin | LR/nt | កម្រ | II | |
| ២ | រញ៉េភ្លើង | *Nycticebus pygmaeus* | Pygmy Loris | Vu | កម្រ | I | |
| ៣ | រញ៉េប្រផេះ | *Nycticebus bengalensis* | Northern Slow Loris | DD | កម្រ | I | |
| ៤ | ស្វាត្រោស | *Macaca leonina* | Northern Pig-Tailed Macaque | Vu | | II | Yes |
| ៥ | ស្វាអង្កត់ | *Macaca arctoides* | Stump-Tailed Macaque | Vu | កម្រ | II | |
| ៦ | ស្វាក្តាម | *Macaca fascicularis* | Long-Tailed Macaque | LR/nt | | II | |
| ៧ | ស្វាព្រាម | *Trachypithecus germaini* | Germain's Silvered Langur | DD | | II | Yes |
| ៨ | ស្វាក្រវ៉ាត់ ឬស្វាកន្ទុយស | *Pygathrix nigripes* | Black-Shanked Douc | En | កម្រ | I | Yes |
| ៩ | ទោចថ្ពាល់លឿង | *Nomascus gabriellae* | Yellow-Cheeked Crested Gibbon | En | កម្រ | I | |
| ១០ | ឆ្កែព្រៃ | *Cuon alpinus* | Dhole | En | កម្រ | II | Yes |
| ១១ | ខ្លាឃ្មុំធំ | *Ursus thibetanus* | Asiatic Black BearDhole | Vu | ជិតផុតពូជ | I | |
| ១២ | ខ្លាឃ្មុំតូច | *Helarctos malayanus* | Sun Bear | DD | កម្រ | I | |
| ១៣ | ភេរោមច្រមុះ | *Lutra sumatrana* | Hairy-Nosed Otter | DD | | II | |
| ១៤ | ភេខ្លួនរលោង | *Lutrogale perspicillata* | Smooth-Coated Otter | Vu | | II | Yes |
| ១៥ | ជ្រូកពោន ឬជ្រូកព្រុល | *Arctonyx collaris* | Hog Badger | | កម្រ | | |
| ១៦ | កំពីងដូង | *Chrotogale owstoni* | Owston's Civet | Vu | | | |
| ១៧ | សំពោចធំ | *Viverra megaspila* | Large-spotted Civet | | | | Yes |
| ១៨ | ឆ្មាព្រៃ | *Felis chaus* | Jungle Cat | | កម្រ | II | Yes |
| ១៩ | ខ្លាត្រី | *Prionailurus viverrinus* | Fishing Cat | Vu | | II | |
| ២០ | ខ្លាលឿងមាស | *Catopuma temminckii* | Asiatic Golden Cat | Vu | កម្រ | I | |
| ២១ | ខ្លាថ្មកែវ | *Pardofelis marmorata* | Marbled Cat | Vu | កម្រ | I | |
| ២២ | ខ្លាពពក | *Neofelis nebulosa* | Clouded Leopard | Vu | កម្រ | I | |
| ២៣ | ខ្លារខិន | *Panthera pardus* | Leopard | | កម្រ | I | Yes |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៤ | ខ្លាធំ ឬខ្លាដំបង | *Panthera tigris* | Tiger | En | ជិតផុតពូជ | I | Yes |
| ២៥ | ដំរី | *Elephas maximus* | Asian Elephant | En | ជិតផុតពូជ | I | Yes |
| ២៦ | ឈ្លូសយក្ស | *Muntiacus vuquangensis* | Large-Antlered Muntjac | DD | | | |
| ២៧ | រមាំង | *Cervus eldii* | Eld's Deer | Vu | ជិតផុតពូជ | | Yes |
| ២៨ | ទន្សោង | *Bos javanicus* | Banteng | En | កម្រ | | Yes |
| ២៩ | គោព្រៃ | *Bos sauveli* | Kouprey | Cr | ជិតផុតពូជ | I | Yes |
| ៣០ | ខ្ទីង | *Bos gaurus* | Gaur | Vu | កម្រ | I | Yes |
| ៣១ | ក្របីព្រៃ | *Bubalus bubalus* | Wild Water Buffalo | En | ជិតផុតពូជ | III | Yes |
| ៣២ | កែះ | *Naemorhedus sumatraensis* | Southern Serow | Vu | កម្រ | I | |
| ៣៣ | កាំប្រម៉ា | *Hystrix brachyuran* | Malayan Porcupine | Vu | | | |
| ៣៤ | កំប្រុកស្លាបធំ | *Petaurista petaurista* | Giant Flying squirrel | | កម្រ | II | |
| ៣៥ | កំប្រុកធំ | *Ratufa afinis* | Black Giant Squirrel` | | កម្រ | II | Yes |

## សត្វស្លាប

| ល.រ | ឈ្មោះ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះ(អង់គ្លេស) | ស្ថានភាពអភិរក្សជាសាកល | ស្ថានភាពអភិរក្សតាមច្បាប់ស្តីពីព្រៃឈើ | ស្ថានភាពការពារតាមអនុសញ្ញាសាយតេស | ប្រភេទអភិរក្សក្នុងតំបន់ព្រៃល្បោះ |
|---|---|---|---|---|---|---|---|
| ១ | ទទាទ្រូងលឿង | *Arborophila davidi* | Orange-Necked Partridge | En | កម្រ | | |
| ២ | រំពេពោះខ្មៅ | *Sterna acuticauda* | Black-bellied Tern | | ជិតផុតពូជ | | Yes |
| ៣ | ក្ងោក | *Pavo muticus* | Green Peafowl | Vu | កម្រ | II | Yes |
| ៤ | ទាព្រៃស្លាបស | *Cairina scutulata* | White-Winged Duck | En | កម្រ | I | Yes |
| ៥ | សេកសោម | *Psittachula eupatria* | Alexadrine Parakeet | | កម្រ | II | Yes |
| ៦ | ពពូលក្បាលព្រលែត | *Columba punicea* | Pale-Capped Pigeon | Vu | កម្រ | | |
| ៧ | ពពូលជើងលឿង | *Treron phoenicoptera* | Yellow-footed Green Pigeon | | | | Yes |
| ៨ | ព្រាបព្រៃ | *Ducula aenea* | Green Imperial Pigeon | | | | Yes |
| ៩ | ក្រៀល | *Grus antigone* | Sarus Crane | Vu | កម្រ | II | Yes |
| ១០ | ពពូលទឹក | *Heliopais personata* | Masked Finfoot | Vu | កម្រ | | Yes |
| ១១ | ត្មាតត្នោត | *Gyps tenuirostris* | Slender-Billed Vulture | Cr | កម្រ | II | Yes |
| ១២ | ត្មាតផេះ | *Gyps bengalensis* | White-Rumped Vulture | Cr | កម្រ | II | Yes |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | ត្មាតភ្លើង | *Sarcogyps calvus* | Red-Headed Vulture | Cr | កម្រ | II | Yes |
| ១៤ | ត្រយ៉ងចំកំកស | *Pseudibis davisoni* | White-Shouldered Ibis | Cr | ជិតផុតពូជ | I | Yes |
| ១៥ | ត្រយ៉ងយក្ស ឬ ឱលើក | *Pseudibis gigantea* | Giant Ibis | Cr | ជិតផុតពូជ | I | Yes |
| ១៦ | ត្រដក់តូច | *Leptoptilos javanicus* | Lesser Adjutant | Vu | កម្រ | I | Yes |
| ១៧ | ចាបដូនតាវាលស្រែ | *Acrocephalus tangorum* | Manchurian Reed Warbler | Vu | | | |
| ១៨ | មាន់ទោប្រាក់ពណ៌ប្រផេះបៃតង | *Polyplectron germaini* | Germain's Pea-cock-Pheasant | LR/nt | កម្រ | II | |
| ១៩ | ស្នោញ | *Anhinga melanogaster* | Oriental Darter | LR/nt | | | Yes |
| ២០ | ស្ដេចកូលីត | *Lophura dairdi* | Siamese Fireback | LR/nt | កម្រ | | Yes |
| ២១ | អង្កត់ខ្មៅ ឬ ដំបងក្រញូង | *Threskiornis melanocephalus* | Black-Necked Stork | LR/nt | ជិតផុតពូជ | II | Yes |
| ២២ | កេងកងធំ | *Buceros bicornis* | Great Hornbill | LR/nt | កម្រ | II | |
| ២៣ | ញាំង | *Aceros undulatus* | Wreathed Hornbill | | កម្រ | II | |
| ២៤ | ទីទុយត្រីថាសត្នោត | *Ketupa zeylonensis* | Brown Fish-owl | | កម្រ | II | |
| ២៥ | ទីទុយត្រីថាសស | *Ketupa ketupu* | Buffy Fish-owl | | កម្រ | II | |
| ២៦ | ទីទុយធំព្រៃ | *Bubo nipalensis* | Spot-bellied Eagle Owl | | កម្រ | II | |
| ២៧ | ស្ទាំងត្នោតស្លាបផែកកំប៉ោយ | *Aviceda jerdoni* | Jerdon's Bazza | | កម្រ | | |
| ២៨ | ស្ទាំងស្លាបស្រួចចុងខ្នងស | *Polihierax insignis* | White-Rumped Falcon | LR/nt | | | Yes |
| ២៩ | ខ្ញប់ដីមេគង្គ | *Motacilla samvaesnaae* | Mekong Wagtails | | កម្រ | | Yes |
| ៣០ | ចាបពូកទ្រូងលឿង | *Ploceus hypoxanthus* | Asian Golden Weaver | | កម្រ | | |

## ឧរង្គសត្វ

| ល.រ | ឈ្មោះ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះ(អង់គ្លេស) | ស្ថានភាពអភិរក្សជាសាកល | ស្ថានភាពអភិរក្សតាមច្បាប់ស្តីពីព្រៃឈើ | ស្ថានភាពការពារតាមអនុសញ្ញាសាយតេស | ប្រភេទអភិរក្សក្នុងតំបន់ព្រៃល្បោះ |
|---|---|---|---|---|---|---|---|
| ១ | ថ្លាន់តូច | *Python molurus* | Burmese Python | LR/nt | | II | |
| ២ | ពស់វែករនាម | *Ophiophagus hannah* | King Cobra | | កម្រ | II | |
| ៣ | ពស់វែកក្របី | *Naja kaouthia* | Monocled Cobra | | កម្រ | II | |
| ៤ | ពស់វែកដំបូក | *Naja siamensis* | Indochinese spitting Cobra | | កម្រ | II | |
| ៥ | ក្រពើត្រី | *Crocodylus siamensis* | Siamese Crocodile | Cr | | I | Yes |
| ៦ | អណ្តើកបិទមុខស្នូកខ្មៅ | *Cuora amboinensis* | South Asian Box Turtle | Vu | | | Yes |
| ៧ | អណ្តើកសោមញី | *Heosemys grandis* | Giant Asian Pond Turtle | Vu | | | Yes |
| ៨ | អណ្តើកក្របីក្បាលលឿង | *Hieremys annandali* | Yellow-Headed Temple Turtle | En | | | Yes |
| ៩ | អណ្តើកព្រិច | *Indotestudo elongata* | Elongated Tortoise | En | | | Yes |
| ១០ | អណ្តើកតឹកកាល់បន្ទាមួយ | *Manouria impressa* | Impressed Tortoise | Vu | | | Yes |
| ១១ | កន្ធាយអាស៊ី | *Amyda cartilaginea* | Asiatic Softshell Turtle | Vu | | | |
| ១២ | អណ្តើកស្រែ | *Malayemys subtrijuga* | Malayan snail-eating Turtle | Vu | | | |
| ១៣ | អណ្តើកក្អែកខ្មៅ | *Siebenrockiella crassicollis* | Black Marsh Turtle | Vu | | | |

## សម្គាល់

- កម្រ : ជាប្រភេទដែលស្ថិតក្នុងក្រុមមានដោយកម្រ និងមានចុះក្នុងប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ០២-កុម្ភៈ-២០០៧ ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះសត្វព្រៃ ។
- ជិតផុតពូជ : ជាប្រភេទដែលស្ថិតក្នុងក្រុមជិតផុតពូជ និងមានចុះក្នុងប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ០២-កុម្ភៈ-២០០៧ ស្តីពីចំណាត់ថ្នាក់ និងបញ្ជីឈ្មោះសត្វព្រៃ ។
- CR : តាមលក្ខណៈវិនិច្ឆ័យនៃសៀវភៅក្រហមរបស់អង្គការ IUCN ជាប្រភេទ "កំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជបំផុត" នៅពេលដែលមានភស្តុតាងច្បាស់លាស់បង្ហាញថា វាកំពុងតែប្រឈមនឹងគ្រោះថ្នាក់ខ្លាំងបំផុតដែលអាចនឹងវិនាសផុតពូជទាំងស្រុងនៅក្នុងព្រៃធម្មជាតិ ។
- EN : តាមលក្ខណៈវិនិច្ឆ័យនៃសៀវភៅក្រហមរបស់អង្គការ IUCN ជាប្រភេទ "កំពុងរងគ្រោះថ្នាក់ជិតផុតពូជ" នៅពេលដែលមានភស្តុតាងច្បាស់លាស់បង្ហាញថា វាកំពុងតែប្រឈមនឹងគ្រោះថ្នាក់ខ្លាំងដែលអាចនឹងវិនាសផុតពូជនៅក្នុងព្រៃធម្មជាតិ ។

- VU : តាមលក្ខណៈវិនិច្ឆ័យនៃសៀវភៅក្រហមរបស់អង្គការ IUCN ជាប្រភេទ "ងាយរងគ្រោះថ្នាក់" នៅពេលដែលមានភស្តុតាងច្បាស់លាស់បង្ហាញថា វាកំពុងតែប្រឈមនឹងគ្រោះថ្នាក់ ដែលអាចឈានទៅរកវិនាសផុតពូជ នៅក្នុងព្រៃធម្មជាតិ។
- LR/nt : តាមលក្ខណៈវិនិច្ឆ័យនៃសៀវភៅក្រហមរបស់អង្គការ IUCN ជាប្រភេទ "រងគ្រោះថ្នាក់តិចតួច" ដែលវាត្រូវបានជិទាស់ទៅនឹងការវិនិច្ឆ័យខាងលើ ព្រោះវាមិនអាចចាត់ថ្នាក់ទៅក្នុងក្រុមណាមួយក្នុងក្រុមទាំងបួនខាងលើ។ ការកើនចំនួន និងការរាយប៉ាយប្រភេទត្រូវបានបញ្ចូលទៅក្នុងលក្ខណៈវិនិច្ឆ័យនេះ ឬអាស្រ័យលើស្ថានភាពអភិរក្សតាមតំបន់ជាក់លាក់ របស់ប្រភេទនោះ។
- YES : ប្រភេទកំពុងមានវត្តមាននៅក្នុងតំបន់ព្រៃឈ្មោះក្នុងខេត្តមណ្ឌលគីរី ។
- I : រួមមានប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលកំពុងទទួលរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជទាំងស្រុង ការធ្វើពាណិជ្ជកម្មលើសំណាកនៃប្រភេទនេះត្រូវហាមឃាត់ដាច់ខាត លើកលែងតែមានការអនុញ្ញាតជាពិសេសតែមួយគត់។
- II : រួមមានប្រភេទសត្វ និងរុក្ខជាតិព្រៃ ដែលនាពេលបច្ចុប្បន្នមិនទាន់ទទួលរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជ ប៉ុន្តែវាអាចនឹងវិនាសផុតពូជ បើសិនជាគ្មានការដាក់បញ្ញត្តិត្រួតពិនិត្យ និងការពារយ៉ាងតឹងរ៉ឹងចំពោះការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទទាំងនេះ។ ទោះបីជាមានប្រភេទខ្លះក្នុងឧបសម្ព័ន្ធនេះបានទទួលការការពារ ឬត្រួតពិនិត្យរួចហើយក៏ដោយក៏ទាមទារឱ្យមានការត្រួតពិនិត្យដ៏មានប្រសិទ្ធិភាពជាបន្ថែមទៀត បើពុំនោះទេវានឹងឈានទៅរកការវិនាសផុតពូជជាមិនខាន។
- III : រួមមានប្រភេទសត្វ និងរុក្ខជាតិព្រៃដែលត្រូវបានទទួលការការពារនិងធ្វើនិយ័តកម្មស្របតាមនីតិវិធីនៃច្បាប់របស់ភាគីដែលជាម្ចាស់ដើមនៃប្រភេទ (ប្រទេសសាម៉ីនៃប្រភេទសត្វ ឬ រុក្ខជាតិ) និងប្រភេទដែលត្រូវស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីប្រទេសជាសមាជិកអនុសញ្ញា ដើម្បីជួយទប់ស្កាត់ឬធ្វើនិយ័តកម្មលើការធ្វើអាជីវកម្មប្រភេទនោះនៅក្នុងយុត្តាធិការនៃដែនទឹកដីរៀងខ្លួន។

# ឯកសារយោង

Balzer, M. C., Nguyen Thi Dao and Shore, R. G. (eds) (2001) *Towards a vision for biodiversity conservation in the Forests of the Lower Mekong Ecoregion Complex.* WWF Indochina/WWF US, Hanoi and Washington D. C.

Dinerstein, E., C. Louck, A. Heydlauff, E. Wikramanayake, G. Brya, J. Ginsberg, S. Klenzendorf, P. Leimgruder, T. O'brien, E. Sanderson, J. Seidensticker and M. Songers, 2006. A user's guide. Setting Priorities for the Conservation and recovery of Wild Tigers 2005-2115, Smithsonian, USA \

Olson, D. M. and Einerstein, E.(2002) The Global 200: priority ecoregions for global conservation. *Annals of the Missour Botanical Garden* 89: 199-224.

Wikramanayake, E., Dinerstein, E., Loucks, C. J., Olson, D. M., Morrison, J., Lamoreux, J., McKnight, M. and Hedao, P. (2002) *Terrestrial ecoregions of the Indo-Pacific. A conservation assessment.* Island Press, Washington D. C.

WWF (2006) *Biodiversity vision for the Lower Mekong Dry Forests Ecoregion Summary Document.* WWF Greater Mekong, Cambodia Country Programme, Phnom Penh.



បេសកកម្មរបស់អង្គការ WWF កម្ពុជា គឺធានាអោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មនុស្សគ្រប់រូប ដើម្បីធ្វើការអភិរក្សជីវចម្រុះដ៏សំបូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អង្គការ WWF កម្ពុជា នឹងជម្រុញអោយមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៏ដល់មនុស្សគ្រប់រូប ក៏ដូចជាការធ្វើអោយប្រសើរឡើងនូវកំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមជាវិភាគទានដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការលើកទឹកចិត្តអោយមាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

បេសកកម្មរបស់អង្គការសមាគមអភិរក្សសត្វព្រៃ (WCS) គឺបំពេញការងារដើម្បីជួយសង្គ្រោះសត្វព្រៃ និងជីវិតសត្វនានាដែលកំពុងរស់នៅក្នុងព្រៃធម្មជាតិ ។ យើងបំពេញសេបកកម្មនេះដោយផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រយ៉ាងហ្មត់ចត់ច្បាស់លាស់ ការអប់រំ ការអភិរក្សដែលមានលក្ខណៈជាសាកល និងការគ្រប់គ្រងដែលដឹកនាំដោយសួនសត្វប្រ៊ុង (Bronx) នូវប្រព័ន្ធឧទ្យានសត្វព្រៃនៅតាមតំបន់ជាយក្រុងដ៏ធំជាងគេនៅក្នុងពិភពលោក ។ សកម្មភាពទាំងនេះ បានធ្វើឱ្យមានការប្រែប្រួលនូវឥរិយាបទនីមួយៗរវាងមនុស្ស ធម្មជាតិ និងសត្វព្រៃ ដោយមានការវិវត្តន៍ឈានឆ្ពោះទៅរកការរស់នៅប្រកបដោយចីរភាពទាំងកម្រិតនៅក្នុងស្រុក និងពិភពលោក។ អង្គការសមាគមអភិរក្សសត្វព្រៃខិតខំបំពេញបេសកកម្មនេះ ព្រោះអង្គការជឿជាក់លើកត្តាសំខាន់នៃជីវិតរស់នៅជាមួយគ្នានៅលើផែនដីតែមួយ។

WWF

*for a living planet*®

© 1986 WWF-World wide Fund for Nature (Formerly World Wildlife Fund)
® Registered Trade mark